# កិច្ចព្រមព្រៀង
# រវាង
# រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
# និង
# រដ្ឋាភិបាលនៃសាធារណរដ្ឋសិង្ហបុរី
# ស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និង
# ការបង្ការការកិបកេងបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល

<u>កំណត់សម្គាល់</u>

កិច្ចព្រមព្រៀងនេះត្រូវបានចុះហត្ថលេខានៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៦
ប្រកាសឱ្យប្រើនៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៧

ក្នុងគោលបំណងឈានទៅសម្រេចកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគិបកេងបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសិង្ហបុរីបានព្រមព្រៀង ដូចតទៅ÷

## មាត្រា ១
## វិសាលភាពលើបុគ្គល

កិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តចំពោះបុគ្គលដែលជានិវាសនជននៃរដ្ឋមួយ ឬរដ្ឋទាំងពីរ ដែលជាភាគីនៃកិច្ចព្រមព្រៀង។

## មាត្រា ២
## វិសាលភាពនៃពន្ធ

១- កិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តចំពោះបណ្តាពន្ធលើប្រាក់ចំណូលដែលកំណត់ដោយរដ្ឋភាគីនៃកិច្ចព្រមព្រៀង ឬអាជ្ញាធរមូលដ្ឋាននៃរដ្ឋនោះ ដោយមិនផ្តោតលើវិធាននៃការកំណត់ពន្ធទាំងនោះ។

២- ពន្ធលើប្រាក់ចំណូលសំដៅដល់បណ្តាពន្ធដែលត្រូវបានកំណត់លើចំណូលសរុប ឬចំណែក នៃចំណូល រួមបញ្ចូលទាំងបណ្តាពន្ធលើចំណេញដែលសម្រេចបានមកពីការលក់ ឬផ្ទេរចលនឬអចលនទ្រព្យ និងបណ្តាពន្ធលើប្រាក់ឈ្នួល ឬប្រាក់បៀវត្សសរុបដែលទូទាត់ដោយសហគ្រាស។

៣- កិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តចំពោះបណ្តាប្រភេទពន្ធ ដូចខាងក្រោម÷

ក. សម្រាប់កម្ពុជា÷

(i) ពន្ធលើប្រាក់ចំណេញ រួមបញ្ចូលទាំងពន្ធកាត់ទុក ពន្ធលើប្រាក់ចំណេញបន្ថែមលើការបែងចែកភាគលាភ និងពន្ធលើចំណេញមូលធន

(ii) ពន្ធលើប្រាក់បៀវត្ស

(តទៅនេះហៅកាត់ថា “ពន្ធរបស់កម្ពុជា”) និង

ខ. សម្រាប់សិង្ហបុរី÷

(i) ពន្ធលើចំណូល

(តទៅនេះហៅកាត់ថា “ពន្ធរបស់សិង្ហបុរី”)។

៤- កិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តផងដែរចំពោះប្រភេទពន្ធណាដែលមានចរិតលក្ខណៈដូចគ្នាសុទ្ធសាធ ឬប្រហាក់ប្រហែលគ្នា ដែលបានដាក់ឱ្យអនុវត្តក្រោយកាលបរិច្ឆេទ នៃការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ដោយបន្ថែម ឬជំនួសឱ្យប្រភេទពន្ធជាធរមាន។ អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងនីមួយៗ ត្រូវជូនដំណឹងគ្នាទៅវិញទៅមកនូវរាល់ការធ្វើវិសោធនកម្មសំខាន់ៗលើច្បាប់ស្តីពីសារពើពន្ធរបស់ខ្លួន។

## មាត្រា ៣
## និយមន័យទូទៅ

១- សម្រាប់គោលដៅនៃកិច្ចព្រមព្រៀងនេះ វៀរលែងតែមានបរិបទដែលតម្រូវឱ្យមានអត្ថន័យផ្សេង÷

ក. ពាក្យ “រដ្ឋភាគីនៃកិច្ចព្រមព្រៀង” សំដៅដល់ព្រះរាជាណាចក្រកម្ពុជា ឬសាធារណរដ្ឋសិង្ហបុរី តាមតម្រូវការនៃបរិបទ។

ខ. ពាក្យ “កម្ពុជា” សំដៅដល់ដែនអធិបតេយ្យភាពនៃព្រះរាជាណាចក្រកម្ពុជា និងតំបន់សមុទ្រ ដែលរួមមាន ខ្ពង់រាបបាតសមុទ្រ និងស្រទាប់ដីក្រោមបាតសមុទ្រ ដែលជាប់នឹងដែនសមុទ្រខាងក្រៅ ហើយដែលព្រះរាជាណាចក្រកម្ពុជាអនុវត្តសិទ្ធិអធិបតេយ្យភាព ឬយុត្តាធិការ ដោយអនុលោមតាមច្បាប់អន្តរជាតិ។

គ. ពាក្យ “សិង្ហបុរី” សំដៅដល់សាធារណរដ្ឋសិង្ហបុរី និងនៅពេលដែលត្រូវប្រើក្នុងបរិបទភូមិសាស្ត្ររួមបញ្ចូលដែនដី ដែនទឹកផ្ទៃក្នុង និងសមុទ្រដែនដី ព្រមទាំងតំបន់សមុទ្រដែលស្ថិតនៅក្រៅសមុទ្រដែនដី ដែលរហូតមកដល់ពេលនេះ ឬអាចក្នុងពេលអនាគត ត្រូវបានកំណត់ដោយច្បាប់ជាតិជាតំបន់ដែលសិង្ហបុរីអាចអនុវត្តសិទ្ធិអធិបតេយ្យ ឬយុត្តាធិការលើសមុទ្រ បាតសមុទ្រ ដីក្រោមបាតសមុទ្រ និងធនធានធម្មជាតិ និងដោយអនុលោមតាមច្បាប់អន្តរជាតិ។

ឃ. ពាក្យ “បុគ្គល” រួមបញ្ចូលរូបវន្តបុគ្គល ក្រុមហ៊ុន និងបុគ្គលដទៃទៀត។

ង. ពាក្យ “ក្រុមហ៊ុន” សំដៅដល់នីតិបុគ្គល ឬអង្គភាពណាមួយដែលត្រូវបានចាត់ទុកជានីតិបុគ្គលសម្រាប់គោលដៅពន្ធ។

ច. ពាក្យ “សហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង” និង “សហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត” សំដៅដល់សហគ្រាសដែលប្រកបអាជីវកម្មដោយនិវាសនជនរបស់រដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង និងសហគ្រាសដែលប្រកបអាជីវកម្មដោយនិវាសជនរបស់រដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត។

ឆ. ពាក្យ “ចរាចរណ៍អន្តរជាតិ” សំដៅដល់ការដឹកជញ្ជូនតាមនាវា ឬយន្តហោះ ដែលធ្វើប្រតិបត្តិការដោយសហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង លើកលែងតែក្នុងករណីនាវា ឬយន្តហោះធ្វើប្រតិបត្តិការ នៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងតែម្ខាងប៉ុណ្ណោះ។

ជ. ពាក្យ “អាជ្ញាធរមានសមត្ថកិច្ច” សំដៅដល់÷

(i) ក្នុងករណីកម្ពុជា÷ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬតំណាងពេញសិទ្ធិរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង

(ii) ក្នុងករណីសិង្ហបុរី÷ រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ ឬតំណាងពេញសិទ្ធិរបស់ក្រសួងហិរញ្ញវត្ថុ។

ឈ. ពាក្យ “ជនជាតិ” នៃរដ្ឋភាគីនៃកិច្ចព្រមព្រៀង សំដៅដល់÷

(i) រូបវន្តបុគ្គលទាំងឡាយដែលជាពលរដ្ឋ ឬមានសញ្ជាតិរបស់រដ្ឋភាគីនៃកិច្ចព្រមព្រៀងនោះ និង

(ii) នីតិបុគ្គល ក្រុមហ៊ុនសហកម្មសិទ្ធិ ឬសមាគមទាំងឡាយណា ដែលត្រូវបានបង្កើតឡើង អនុ-លោមតាមច្បាប់ជាធរមាននៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងនោះ។

២- សម្រាប់គោលដៅនៃមាត្រា១០ មាត្រា១១ និងមាត្រា១២ បរធនបាលដែលជាប់ពន្ធក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងចំពោះភាគលាភ ការប្រាក់ ឬសួយសារ ត្រូវចាត់ទុកជាម្ចាស់ទទួលផលកម្រៃនៃភាគលាភ ការប្រាក់ ឬសួយសារទាំងនោះ។

៣- ចំពោះការអនុវត្តកិច្ចព្រមព្រៀងដោយរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ក្នុងពេលដែលពាក្យណាមួយមិនបានកំណត់និយមន័យនៅក្នុងកិច្ចព្រមព្រៀងនេះ ពាក្យនោះត្រូវមានន័យដូចដែលមានចែងក្នុងច្បាប់របស់រដ្ឋនោះ សម្រាប់គោលដៅយកពន្ធដែលស្របតាមកិច្ចព្រមព្រៀងនេះ វៀរលែងតែមានបរិបទតម្រូវឱ្យមានអត្ថន័យផ្សេង។ និយមន័យនៃពាក្យណាមួយដែលមានចែងក្នុងច្បាប់ស្តីពីសារពើពន្ធរបស់រដ្ឋនោះ ត្រូវមានវិសាលភាពគ្របដណ្តប់លើនិយមន័យដែលមានចែង ក្នុងច្បាប់ដទៃទៀតរបស់រដ្ឋនោះ។

## មាត្រា ៤
## និវាសនជន

១- សម្រាប់គោលដៅនៃកិច្ចព្រមព្រៀងនេះ ពាក្យ “និវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀង” សំដៅដល់បុគ្គលណាមួយ ដែលជាប់ពន្ធនៅក្រោមច្បាប់របស់រដ្ឋនោះ ដោយសារមានលំនៅដ្ឋាន និវាសនដ្ឋាន ទីកន្លែងចុះបញ្ជីរបស់ក្រុមហ៊ុន ទីកន្លែងសម្រាប់ធ្វើការងារគ្រប់គ្រង ទីកន្លែងប្រកបអាជីវកម្មជាគោលដើម ឬលក្ខណវិនិច្ឆ័យផ្សេងទៀត ដែលមានភាពប្រហាក់ប្រហែល ដោយរួមបញ្ចូលផងដែរទាំងរដ្ឋនោះ និងអាជ្ញាធរមូលដ្ឋាន ឬនីតិបុគ្គលសាធារណៈនៃរដ្ឋនោះ។

២- យោងតាមបញ្ញត្តិនៃកថាខណ្ឌ១ ក្នុងករណីដែលបុគ្គលម្នាក់ជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងទាំងពីរ ស្ថានភាពរបស់បុគ្គលនោះ ត្រូវបានកំណត់ដូចខាងក្រោម÷

ក. បុគ្គលនោះត្រូវបានចាត់ទុកជានិវាសនជនរបស់រដ្ឋម្ខាងប៉ុណ្ណោះ ដែលបុគ្គលនោះមានលំនៅដ្ឋានអចិន្ត្រៃយ៍នៅក្នុងរដ្ឋនោះ។ ប្រសិនបើបុគ្គលនោះមានលំនៅដ្ឋានអចិន្ត្រៃយ៍នៅក្នុងរដ្ឋទាំងពីរ បុគ្គលនោះត្រូវចាត់ទុកជានិវាសនជនតែក្នុងរដ្ឋមួយដែលមានទំនាក់ទំនងផ្ទាល់ខ្លួន និងសេដ្ឋកិច្ចជិតស្និទ្ធជាង (មូលដ្ឋានផលប្រយោជន៍សំខាន់)។

ខ. ប្រសិនបើពុំអាចកំណត់រដ្ឋដែលបុគ្គលនោះមានមូលដ្ឋានផលប្រយោជន៍សំខាន់ៗបាន ឬបុគ្គលនោះគ្មានលំនៅដ្ឋានអចិន្ត្រៃយ៍សម្រាប់ស្នាក់នៅក្នុងរដ្ឋណាមួយ បុគ្គលនោះត្រូវចាត់ទុកជានិវាសនជនតែក្នុងរដ្ឋម្ខាងដែលបុគ្គលនោះមានកន្លែងស្នាក់នៅជាទម្លាប់។

គ. ប្រសិនបើបុគ្គលនោះមាន ឬគ្មានកន្លែងស្នាក់នៅជាទម្លាប់នៅក្នុងរដ្ឋទាំងពីរ បុគ្គលនោះត្រូវចាត់ទុកជានិវាសនជនតែក្នុងរដ្ឋម្ខាង ដែលបុគ្គលនោះមានសញ្ជាតិ។

ឃ. ក្នុងករណីដទៃទៀត អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងទាំងពីរ ត្រូវដោះស្រាយបញ្ហាតាមរយៈការព្រមព្រៀងទៅវិញទៅមក។

៣- យោងតាមបញ្ញត្តិនៃកថាខណ្ឌ១ ក្នុងករណីបុគ្គលដែលមិនមែនជារូបវន្តបុគ្គល ជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងទាំងពីរ អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងទាំងពីរ ត្រូវដោះស្រាយបញ្ហាតាមរយៈការព្រមព្រៀងទៅវិញទៅមក។

# មាត្រា ៥
# គ្រឹះស្ថានអចិន្ត្រៃយ៍

១- សម្រាប់គោលដៅនៃកិច្ចព្រមព្រៀងនេះ ពាក្យ "គ្រឹះស្ថានអចិន្ត្រៃយ៍" សំដៅដល់ទីកន្លែងប្រកបអាជីវកម្មជាប់លាប់ ដែលសហគ្រាសដំណើរការប្រកបអាជីវកម្មទាំងស្រុង ឬផ្នែកណាមួយនៃអាជីវកម្ម។

២- ពាក្យ "គ្រឹះស្ថានអចិន្ត្រៃយ៍" មានជាអាទិ៍÷

ក. ទីកន្លែងសម្រាប់ធ្វើការងារគ្រប់គ្រង

ខ. សាខារបស់សហគ្រាសបរទេស

គ. ការិយាល័យ

ឃ. រោងចក្រ

ង. រោងជាង

ច. ឃ្លាំង ដែលបុគ្គលផ្តល់ទីតាំងសម្រាប់ស្តុកទំនិញឱ្យបុគ្គលដទៃ

ឆ. ទីតាំងរុករករ៉ែ អណ្តូងប្រេងកាត ឬឧស្ម័នធម្មជាតិ ទីតាំងវាយយកថ្ម ឬទីតាំងយកធនធានធម្មជាតិផ្សេងៗ និង

ជ. កសិដ្ឋាន ឬកន្លែងដាំដុះ (ចំការ)។

៣- ពាក្យ "គ្រឹះស្ថានអចិន្ត្រៃយ៍" ក៏រួមបញ្ចូលផងដែរ÷

ក. ការដ្ឋានសំណង់អគារ គម្រោងសាងសង់ឬគម្រោងបង្គុំឬដំឡើង ឬសកម្មភាពតាមដានពិនិត្យ ដែលជាប់ទាក់ទិននឹងទីតាំងឬគម្រោងទាំងនោះ ក៏ប៉ុន្តែលុះត្រាការដ្ឋាន ឬគម្រោង ឬសកម្មភាពទាំងនោះមានរយៈពេលលើសពី ៦ខែ។

ខ. ការផ្តល់សេវា ដែលរួមមានទាំងសេវាប្រឹក្សាដែលធ្វើឡើងដោយសហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង តាមរយៈនិយោជិក ឬបុគ្គលិកផ្សេងទៀតជួលដោយសហគ្រាសនោះ ក្នុងគោលដៅខាងលើ លុះត្រាតែសកម្មភាពទាំងនោះបានប្រព្រឹត្តទៅជាបន្តបន្ទាប់ (សម្រាប់គម្រោងដូចគ្នា ឬពាក់ព័ន្ធគ្នា) មួយលើក ឬច្រើនលើក ដែលមានរយៈពេលសរុបលើសពី ១៨៣ថ្ងៃ ក្នុងអំឡុងពេល ១២ខែ ណាមួយ នៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត។

គ. សកម្មភាពអាជីវកម្ម (រួមបញ្ចូលទាំងប្រតិបត្តិការឧបករណ៍ធុនធ្ងន់) នៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀតសម្រាប់ការស្វែងរុករក ឬការធ្វើអាជីវកម្មធនធានធម្មជាតិ សម្រាប់មួយលើក ឬច្រើនលើក ដែលមានរយៈពេលសរុបលើសពី ៩០ថ្ងៃ ក្នុងអំឡុងពេល ១២ខែ ណាមួយ។

៤- ទោះបីជាមានបញ្ញត្តិខាងលើនៃមាត្រានេះក៏ដោយ ពាក្យ“គ្រឹះស្ថានអចិន្ត្រៃយ៍” មិនត្រូវបានចាត់ទុកថារាប់បញ្ចូល÷

ក. ការប្រើប្រាស់នូវទីតាំងសម្រាប់តែគោលដៅក្នុងការស្តុកទុក ការតាំងបង្ហាញ ឬការបញ្ជូនទំនិញ ឬផលិតផល ដែលជាកម្មសិទ្ធិរបស់សហគ្រាស

ខ. ការថែទាំទំនិញក្នុងស្តុក ឬផលិតផល ដែលជាកម្មសិទ្ធិរបស់សហគ្រាស សម្រាប់តែគោលដៅក្នុងការស្តុកទុក ការតាំងបង្ហាញ ឬការបញ្ជូន

គ. ការថែទាំទំនិញក្នុងស្តុក ឬផលិតផល ដែលជាកម្មសិទ្ធិរបស់សហគ្រាស សម្រាប់តែគោលដៅក្នុងការកែច្នៃដោយសហគ្រាសដទៃទៀត

ឃ. ការរក្សាទីកន្លែងប្រកបអាជីវកម្មជាប់លាប់ សម្រាប់តែគោលដៅក្នុងការទិញទំនិញ ឬផលិតផល ឬការប្រមូលព័ត៌មានសម្រាប់សហគ្រាស

ង. ការរក្សាទីកន្លែងប្រកបអាជីវកម្មជាប់លាប់ សម្រាប់តែគោលដៅនៃសកម្មភាពផ្សេងទៀតរបស់សហគ្រាសដែលមានចរិតលក្ខណៈត្រៀមបម្រុងទុក ឬបន្ទាប់បន្សំ និង

ច. ការរក្សាទីកន្លែងប្រកបអាជីវកម្មជាប់លាប់ សម្រាប់តែសកម្មភាពរួមផ្សំគ្នាណាមួយ នៃសកម្មភាពដែលមានចែងក្នុងវាក្យខណ្ឌ (ក) ដល់ (ង) ក្នុងលក្ខខណ្ឌដែលសកម្មភាពទាំងមូលរបស់ទីកន្លែងប្រកបអាជីវកម្មជាប់លាប់ដែលជាលទ្ធផលនៃការរួមផ្សំគ្នានេះ មានចរិតលក្ខណៈត្រៀមបម្រុងទុក ឬបន្ទាប់បន្សំ។

៥- ទោះបីជាមានបញ្ញត្តិក្នុងកថាខណ្ឌ១ និង២ ក៏ដោយ បុគ្គល (ក្រៅពីភ្នាក់ងារមានលក្ខណៈឯករាជ្យដែលកថាខណ្ឌ៧ អនុវត្ត) បំពេញសកម្មភាពនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ក្នុងនាមសហគ្រាសមួយនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត សហគ្រាសនោះត្រូវបានចាត់ទុកថាមានគ្រឹះស្ថានអចិន្ត្រៃយ៍ក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងដែលបានលើកឡើងពីខាងដើម ចំពោះបណ្តាសកម្មភាពដែលធ្វើឡើងក្នុងនាមសហគ្រាស ក្នុងករណីដែលបុគ្គលនោះ÷

ក. មាន និងអនុវត្តសិទ្ធិជាប្រចាំលើការចុះកិច្ចសន្យាក្នុងនាមសហគ្រាសនៅក្នុងរដ្ឋនោះ វៀរលែងតែសកម្មភាពទាំងនោះត្រូវបានកំណត់ដូចមានចែងក្នុងកថាខណ្ឌ៤ខាងលើ ទោះបីសកម្មភាពនោះធ្វើឡើងតាមរយៈទីកន្លែងប្រកបអាជីវកម្មជាប់លាប់ក៏ដោយ ទីកន្លែងប្រកបអាជីវកម្មជាប់លាប់នោះ មិនត្រូវបានចាត់ទុកថាជាគ្រឹះស្ថានអចិន្ត្រៃយ៍ក្រោមបញ្ញត្តិនៃកថាខណ្ឌ៤ នោះឡើយ ឬ

ខ. ពុំមានសិទ្ធិក្នុងការចុះកិច្ចសន្យា ប៉ុន្តែថែរក្សាស្តុកទំនិញឬផលិតផលជាប្រចាំ នៅក្នុងរដ្ឋខាងដើមដែលតែងតែបញ្ជូនទំនិញ ឬផលិតផលក្នុងនាមសហគ្រាសជាទៀងទាត់។

៦-	ទោះបីជាមានបញ្ញត្តិខាងដើមនៃមាត្រានេះក៏ដោយ វៀរលែងតែពាក់ព័ន្ធនឹងការធានារ៉ាប់រងបន្ត សហគ្រាសធានារ៉ាប់រងនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ត្រូវចាត់ទុកថាមានគ្រឹះស្ថានអចិន្ត្រៃយ៍នៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត ប្រសិនបើសហគ្រាសនោះ ប្រមូលបុព្វលាភនៅក្នុងទឹកដីនៃរដ្ឋម្ខាងទៀតនោះ ឬធានារ៉ាប់រងហានិភ័យផ្សេងៗ ដែលស្ថិតនៅក្នុងទឹកដីនៃរដ្ឋនោះ តាមរយៈបុគ្គលក្រៅពីភ្នាក់ងារមានលក្ខណៈឯករាជ្យ ដែលអនុវត្តតាមកថាខណ្ឌ៧។

៧-	សហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង មិនត្រូវចាត់ទុកថាមានគ្រឹះស្ថានអចិន្ត្រៃយ៍នៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត ដោយគ្រាន់តែប្រកបអាជីវកម្មក្នុងរដ្ឋម្ខាងទៀតនោះ តាមរយៈឈ្មួញកណ្តាល ភ្នាក់ងារកម្រៃជើងសារទូទៅ ឬភ្នាក់ងារដទៃទៀតដែលមានលក្ខណៈឯករាជ្យ ក្នុងលក្ខខណ្ឌដែលបុគ្គលទាំងនោះ បំពេញសកម្មភាពដែលជាដំណើរការប្រក្រតីនៃអាជីវកម្មរបស់ខ្លួនប៉ុណ្ណោះ។ ទោះបីជាយ៉ាងណាក៏ដោយ ភ្នាក់ងារនោះនឹងមិនត្រូវបានចាត់ទុកជាភ្នាក់ងារមានលក្ខណៈឯករាជ្យក្នុងខ្លឹមសារនៃកថាខណ្ឌនេះ នៅពេលដែលសកម្មភាពរបស់ភ្នាក់ងារនោះ បម្រើផលប្រយោជន៍ទាំងស្រុង ឬស្ទើរតែទាំងស្រុងក្នុងនាមសហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងនោះ និងលក្ខខណ្ឌទាំងឡាយដែលបានធ្វើឬកំណត់ឡើងរវាងសហគ្រាស និងភ្នាក់ងារក្នុងទំនាក់ទំនងពាណិជ្ជកម្ម និងហិរញ្ញវត្ថុដែលខុសគ្នាពីលក្ខខណ្ឌដែលបានធ្វើឡើងរវាងសហគ្រាសឯករាជ្យដទៃទៀត។

៨-	ក្នុងករណីដែលក្រុមហ៊ុនជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង គ្រប់គ្រង ឬត្រូវបានគ្រប់គ្រងដោយក្រុមហ៊ុនដែលជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត ឬដែលប្រកបអាជីវកម្មនៅក្នុងរដ្ឋម្ខាងទៀតនោះ (ទោះបីជាតាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍ ឬមិនមែនតាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍) មិនត្រូវចាត់ទុកក្រុមហ៊ុនណាមួយ ជាគ្រឹះស្ថានអចិន្ត្រៃយ៍នៃក្រុមហ៊ុនណាមួយទៀតឡើយ។

## មាត្រា ៦
## ប្រាក់ចំណូលពីអចលនទ្រព្យ

១- ប្រាក់ចំណូលដែលទទួលបានដោយនិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ពីអចលនទ្រព្យ (រួមបញ្ចូលទាំងប្រាក់ចំណូលពីកសិកម្ម ឬរុក្ខាប្រមាញ់) ដែលស្ថិតនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត អាចត្រូវជាប់ពន្ធនៅក្នុងរដ្ឋម្ខាងទៀតនោះ។

២- ពាក្យ "អចលនទ្រព្យ" ត្រូវមានន័យដូចមានចែងក្នុងច្បាប់នៃរដ្ឋភាគីនៃកិច្ចព្រមព្រៀង ដែលអចលនទ្រព្យនោះស្ថិតនៅ។ ក្នុងករណីណាក៏ដោយ ពាក្យនេះត្រូវរួមបញ្ចូលផងដែរនូវទ្រព្យបន្ទាប់បន្សំនៃអចលនទ្រព្យ បសុសត្វ និងឧបករណ៍ប្រើប្រាស់នៅក្នុងកសិកម្មនិងរុក្ខាប្រមាញ់ សិទ្ធិដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ទូទៅដែលទាក់ទិននឹងទ្រព្យសម្បត្តិដែលបង្កើតចំណូល សិទ្ធិប្រើប្រាស់និងអាស្រ័យផលលើអចលនទ្រព្យ និងសិទ្ធិទទួលបានការទូទាត់ក្នុងចំនួនជាក់លាក់ ឬប្រែប្រួលតាមលទ្ធផលជាក់ស្តែងសម្រាប់ការប្រកបអាជីវកម្ម ឬសិទ្ធិប្រកបអាជីវកម្មលើជម្រករ៉ែ ប្រភពធនធានរ៉ែ និងធនធានធម្មជាតិផ្សេងទៀត។ នាវា ទូក និងយន្តហោះមិនត្រូវចាត់ទុកជាអចលនទ្រព្យឡើយ។

៣- បញ្ញត្តិក្នុងកថាខណ្ឌ១ ត្រូវអនុវត្តផងដែរចំពោះប្រាក់ចំណូលដែលទទួលបានពីការប្រើប្រាស់ផ្ទាល់ ការជួល ឬការប្រើប្រាស់ក្នុងរូបភាពផ្សេងទៀតនៃអចលនទ្រព្យ។

៤- បញ្ញត្តិក្នុងកថាខណ្ឌ១ និង៣ ត្រូវអនុវត្តផងដែរចំពោះប្រាក់ចំណូលពីអចលនទ្រព្យរបស់សហគ្រាស និងចំពោះប្រាក់ចំណូលពីអចលនទ្រព្យដែលបានប្រើប្រាស់សម្រាប់បំពេញសេវាបុគ្គលឯករាជ្យ។

## មាត្រា ៧
## ប្រាក់ចំណេញអាជីវកម្ម

១- ប្រាក់ចំណេញរបស់សហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ត្រូវជាប់ពន្ធតែក្នុងរដ្ឋនោះប៉ុណ្ណោះ វៀរលែងតែសហគ្រាសនោះ ប្រកបអាជីវកម្មក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត តាមរយៈគ្រឹះស្ថានអចិ-ន្ត្រៃយ៍ដែលស្ថិតនៅក្នុងរដ្ឋម្ខាងទៀតនោះ។ ក្នុងករណីដែលសហគ្រាសនោះប្រកបអាជីវកម្មដូចបានរៀបរាប់ខាងលើ ប្រាក់ចំណេញរបស់សហគ្រាស អាចជាប់ពន្ធនៅក្នុងរដ្ឋម្ខាងទៀតនោះ លើតែប្រាក់ចំណេញណាដែលសម្រេចបានពីគ្រឹះស្ថានអចិន្ត្រៃយ៍នោះប៉ុណ្ណោះ។

២- សម្រាប់គោលដៅបញ្ញត្តិនៃកថាខណ្ឌ៣ ក្នុងករណីសហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងប្រកបអាជីវកម្មនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត តាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍ដែលស្ថិតនៅក្នុងរដ្ឋម្ខាងទៀតនោះ ប្រាក់ចំណេញដែលកើតពីគ្រឹះស្ថានអចិន្ត្រៃយ៍នៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងនីមួយៗ ត្រូវបានកំណត់ដូចប្រាក់ចំណេញនៃសហគ្រាសផ្សេងទៀត និងដាច់ដោយឡែកពីគ្នា ដែលមានសកម្មភាពអាជីវកម្មដូច ឬប្រហាក់ប្រហែលគ្នា ក្រោមលក្ខខណ្ឌដូច ឬប្រហាក់ប្រហែលគ្នា ដែលមានសកម្មភាពអាជីវកម្មឯករាជ្យទាំងស្រុងពីសហគ្រាសដែលមានគ្រឹះស្ថានអចិន្ត្រៃយ៍នោះ។

៣- ក្នុងការកំណត់ប្រាក់ចំណេញរបស់គ្រឹះស្ថានអចិន្ត្រៃយ៍ ត្រូវអនុញ្ញាតឱ្យកាត់កងរាល់ចំណាយទាំងអស់ដែលរួមបញ្ចូលទាំងចំណាយសម្រាប់ប្រតិបត្តិការ និងរដ្ឋបាលទូទៅ ដែលអាចអនុញ្ញាតឱ្យកាត់កងទៅតាមកម្រិតចំណាយសមហេតុផលនៃគ្រឹះស្ថានអចិន្ត្រៃយ៍ ប្រសិនបើគ្រឹះស្ថានអចិន្ត្រៃយ៍នោះជាសហគ្រាសឯករាជ្យ ដោយមិនគិតថាចំណាយទាំងនោះ កើតឡើងនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងដែលគ្រឹះស្ថានអចិន្ត្រៃយ៍ស្ថិតនៅ ឬនៅកន្លែងផ្សេងទៀត។

៤- សម្រាប់គោលដៅនៃបណ្តាកថាខណ្ឌខាងលើនេះ ការកំណត់ប្រាក់ចំណេញដែលសម្រេចបានដោយគ្រឹះស្ថានអចិន្ត្រៃយ៍ ត្រូវប្រើប្រាស់វិធានដូចគ្នាពីមួយឆ្នាំទៅមួយឆ្នាំ។ ការអនុវត្តផ្ទុយពីនេះ អាចប្រព្រឹត្តទៅបានលុះត្រាតែមានហេតុផលសមរម្យ និងគ្រប់គ្រាន់។

៥- គ្មានបញ្ញត្តិណាមួយនៃមាត្រានេះ ធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តច្បាប់ណាមួយរបស់រដ្ឋភាគីនៃកិច្ចព្រមព្រៀង ទាក់ទិននឹងការកំណត់ពន្ធលើប្រាក់ចំណូលពីការលក់ធានារ៉ាប់រងរបស់ក្រុមហ៊ុនធានារ៉ាប់រងអនិវាសជនដែលមានគ្រឹះស្ថានអចិន្ត្រៃយ៍នៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងនោះឡើយ លើកលែងតែការធានារ៉ាប់រងបន្ត។

**៦-** ក្នុងករណីដែលប្រាក់ចំណេញរួមបញ្ចូលទាំងប្រភេទប្រាក់ចំណូលផ្សេងៗ ដែលបានចែងដាច់ដោយឡែកនៅក្នុងមាត្រាផ្សេងទៀតនៃកិច្ចព្រមព្រៀងនេះ បញ្ញត្តិរបស់មាត្រាទាំងនោះមិនត្រូវបានគ្របដណ្តប់ ដោយបញ្ញត្តិនៃមាត្រានេះទេ។

## មាត្រា ៨
## ការដឹកជញ្ជូនអន្តរជាតិ

១- ប្រាក់ចំណេញដែលទទួលបានដោយសហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀង ពីប្រតិបត្តិការនៃយន្តហោះក្នុងចរាចរណ៍អន្តរជាតិ ត្រូវជាប់ពន្ធនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងនោះតែប៉ុណ្ណោះ។

២- ប្រាក់ចំណេញដែលទទួលបានដោយសហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀង ពីប្រតិបត្តិការនៃនាវាក្នុងចរាចរណ៍អន្តរជាតិ អាចជាប់ពន្ធនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត ប៉ុន្តែការកំណត់ពន្ធនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀតនោះ ត្រូវកាត់បន្ថយ ៥០ ភាគរយ។

៣- បញ្ញត្តិក្នុងកថាខណ្ឌ១ និង២ ត្រូវអនុវត្តផងដែរចំពោះប្រាក់ចំណេញពីការចូលរួមជាក្រុម ឬចង្កោមអាជីវកម្មរួមគ្នា ឬទីភ្នាក់ងារប្រត្តិបត្តិការអន្តរជាតិ។

## មាត្រា ៩
## សហគ្រាសដែលមានការទាក់ទងគ្នា

១- ក្នុងករណី÷

ក. សហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ចូលរួមដោយផ្ទាល់ ឬដោយប្រយោលក្នុងការចាត់ចែង ការគ្រប់គ្រង ឬមានដើមទុននៅក្នុងសហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត ឬ

ខ. បុគ្គលតែមួយ ចូលរួមដោយផ្ទាល់ ឬដោយប្រយោលក្នុងការចាត់ចែង ការគ្រប់គ្រង ឬមានដើមទុននៅក្នុងសហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងនិងសហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត

ហើយនៅក្នុងករណីមួយណាក៏ដោយ លក្ខខណ្ឌត្រូវបានធ្វើឡើង ឬកំណត់ រវាងសហគ្រាសទាំងពីរ នៅក្នុងទំនាក់ទំនងផ្នែកពាណិជ្ជកម្ម ឬផ្នែកហិរញ្ញវត្ថុ ដែលខុសគ្នាពីលក្ខខណ្ឌដែលត្រូវបានធ្វើឡើងរវាងបណ្តាសហគ្រាសឯករាជ្យ ដូចនេះ ប្រាក់ចំណេញដែលអាចត្រូវបង្គរដោយសហគ្រាសណាមួយ នៅក្នុងចំណោមសហគ្រាសដែលមានទំនាក់ទំនងទាំងនោះ ប៉ុន្តែពុំត្រូវបង្គរជាប្រាក់ចំណេញដោយហេតុផលនៃបណ្តាលក្ខខណ្ឌខាងលើ ប្រាក់ចំណេញនោះក៏អាចត្រូវរាប់បញ្ចូលជាប្រាក់ចំណេញរបស់សហគ្រាសនោះ និងត្រូវជាប់ពន្ធស្របតាមនីតិវិធីនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀង។

២- ក្នុងករណីរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង រាប់បញ្ចូលប្រាក់ចំណេញរបស់សហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀតទៅក្នុងប្រាក់ចំណេញរបស់សហគ្រាសនៃរដ្ឋភាគីដំបូង ហើយបានយកពន្ធទៅតាមនីតិវិធីជាធរមាន ដែលប្រាក់ចំណេញដែលបានរាប់បញ្ចូលនោះ ត្រូវបានយកពន្ធរួចហើយដោយរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត ហើយប្រាក់ចំណេញដែលដាក់បញ្ចូលនោះ គឺជាប្រាក់ចំណេញដែលគួរត្រូវបានទទួលដោយសហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងដំបូង ប្រសិនបើលក្ខខណ្ឌដែលបានធ្វើឡើងរវាងសហគ្រាសទាំងពីរនេះដូចលក្ខខណ្ឌដែលបានធ្វើរវាងសហគ្រាសឯករាជ្យ ដូចនេះ រដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀតត្រូវធ្វើនិយ័តកម្មឱ្យបានសមស្របលើប្រាក់ពន្ធដែលជាប្រាក់ចំណេញរបស់ខ្លួន។ ក្នុងការកំណត់និយ័តកម្មបែបនេះ បញ្ញត្តិពាក់ព័ន្ធដទៃទៀតនៃកិច្ចព្រមព្រៀងត្រូវអនុវត្តជាចាំបាច់ ហើយអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងទាំងពីរត្រូវធ្វើការពិភាក្សាគ្នា ប្រសិនបើមានការចាំបាច់។

## មាត្រា ១០
## ភាគលាភ

១- ភាគលាភដែលត្រូវបានទូទាត់ដោយក្រុមហ៊ុននិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ឱ្យទៅនិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត អាចជាប់ពន្ធក្នុងរដ្ឋម្ខាងទៀតនោះ។

២- ភាគលាភនោះក៏អាចជាប់ពន្ធនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងដែលក្រុមហ៊ុនទូទាត់ភាគលាភនោះ ជានិវាសនជនផងដែរ ដោយអនុលោមទៅតាមច្បាប់នៃរដ្ឋនោះ ប៉ុន្តែប្រសិនបើម្ចាស់សិទ្ធិអាស្រ័យផលនៃភាគលាភនោះ ជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត បន្ទុកពន្ធដែលត្រូវបង់មិនត្រូវលើសពី ១០ភាគរយនៃចំនួនដុល នៃភាគលាភ។ កថាខណ្ឌនេះមិនប៉ះពាល់ដល់ការយកពន្ធលើក្រុមហ៊ុនចំពោះប្រាក់ចំណេញដែលជាប្រភពនៃភាគលាភដែលបានទូទាត់។

៣- ពាក្យ “ភាគលាភ” ដែលប្រើក្នុងមាត្រានេះ សំដៅដល់ប្រាក់ចំណូលដែលបានមកពីភាគហ៊ុននានា ភាគហ៊ុនក្នុងវិស័យរ៉ែ ភាគហ៊ុនរបស់អ្នកបង្កើត ឬសិទ្ធិផ្សេងៗដែលមិនមែនជាឥណទេយ្យបំណុល ប៉ុន្តែចូលរួមទទួលប្រាក់ចំណេញ ក៏ដូចជាចំណូលបានមកពីសិទ្ធិក្នុងក្រុមហ៊ុនដែលត្រូវបានកំណត់ពន្ធដូចគ្នាទៅនឹងប្រាក់ចំណូលបានពីភាគហ៊ុន ដែលកំណត់ដោយច្បាប់នៃរដ្ឋដែលក្រុមហ៊ុនបែងចែកភាគលាភនោះជានិវាសនជន។

៤- បញ្ញត្តិក្នុងកថាខណ្ឌ១ និង២ មិនត្រូវយកមកអនុវត្ត ប្រសិនបើម្ចាស់សិទ្ធិអាស្រ័យផល នៃភាគលាភជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ប្រកបអាជីវកម្មនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀតដែលក្រុមហ៊ុនទូទាត់ភាគលាភជានិវាសនជន តាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍ ឬបំពេញសេវាបុគ្គលឯករាជ្យតាមរយៈមូលដ្ឋានជាប់លាប់ ដែលស្ថិតនៅរដ្ឋម្ខាងទៀតនោះ និងការកាន់កាប់ភាគហ៊ុនដែលនាំឱ្យមានការទូទាត់ភាគលាភនោះ មានទំនាក់ទំនងជាក់លាក់ជាមួយគ្រឹះស្ថានអចិន្ត្រៃយ៍ ឬមូលដ្ឋានជាប់លាប់នោះ។ ចំពោះករណីនេះ បញ្ញត្តិនៃមាត្រា៧ ឬមាត្រា១៥ ត្រូវយកមកអនុវត្ត។

៥- ក្នុងករណីក្រុមហ៊ុនដែលជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ទទួលប្រាក់ចំណេញ ឬប្រាក់ចំណូលមកពីរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត រដ្ឋម្ខាងទៀតនោះ អាចមិនត្រូវកំណត់ពន្ធទៅលើភាគលាភដែលបានទូទាត់ដោយក្រុមហ៊ុនដែលជានិវាសនជននៃរដ្ឋភាគីដំបូងនោះទេ លើកលែងតែភាគលាភទាំងនោះត្រូវបានទូទាត់ទៅឱ្យនិវាសនជននៃរដ្ឋម្ខាងទៀត ឬការកាន់កាប់ភាគហ៊ុនដែលនាំឱ្យមានការទូទាត់ភាគលាភនោះ មានទំនាក់ទំនងជាក់លាក់ជាមួយគ្រឹះស្ថានអចិន្ត្រៃយ៍ ឬមូលដ្ឋានជាប់លាប់នៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀតនោះ។ ដូចនេះ ប្រាក់ចំណេញដែលមិនបានបែងចែករបស់ក្រុមហ៊ុនដែលជានិវាសនជននៃរដ្ឋភាគីដំបូង មិនគួរជាកម្មវត្ថុនៃការកំណត់ពន្ធលើប្រាក់ចំណេញមិនបានបែងចែករបស់ក្រុមហ៊ុន ដោយរដ្ឋម្ខាង

ទៀតនោះ ទោះបីជាភាគលាភដែលបានទូទាត់ ឬប្រាក់ចំណេញ មិនបានបែងចែក មានចំណែកខ្លះ ឬទាំងស្រុងពីប្រាក់ចំណេញ ឬប្រាក់ចំណូលដែលបានកើតឡើងក្នុងរដ្ឋម្ខាងទៀតនោះ ក៏ដោយ។

## មាត្រា ១១
## ការប្រាក់

១- ការប្រាក់ដែលកើតឡើងនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ហើយត្រូវបានទូទាត់ទៅឱ្យនិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត អាចជាប់ពន្ធនៅក្នុងរដ្ឋម្ខាងទៀតនោះ។

២- ការប្រាក់នោះក៏អាចជាប់ពន្ធនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងដែលការប្រាក់នោះកើតឡើងផងដែរ និងអនុលោមតាមច្បាប់នៃរដ្ឋនោះ ប៉ុន្តែប្រសិនបើម្ចាស់សិទ្ធិអាស្រ័យផលនៃការប្រាក់នោះ ជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត បន្ទុកពន្ធដែលត្រូវបង់មិនត្រូវឱ្យលើសពី ១០ ភាគរយ នៃចំនួនដុលនៃការប្រាក់នោះទេ។

៣- ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌ២ ក៏ដោយ ការប្រាក់ដែលកើតឡើងនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង និងបានទូទាត់ទៅឱ្យរដ្ឋាភិបាលនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត ត្រូវបានលើកលែងពន្ធនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងដំបូង។

សម្រាប់គោលបំណងនៃកថាខណ្ឌនេះ ពាក្យ “រដ្ឋាភិបាល” ៖

ក. សម្រាប់កម្ពុជា រួមមាន ៖

(i) រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

(ii) ធនាគារជាតិនៃកម្ពុជា ឬអាជ្ញាធរមូលដ្ឋាន

(iii) ធនាគារអភិវឌ្ឍន៍ជនបទ

(iv) នីតិបុគ្គលសាធារណៈ និង

(v) ស្ថាប័នដទៃទៀតដូចដែលអាចព្រមព្រៀងគ្នានាពេលក្រោយ រវាងអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងទាំងពីរ។

ខ. សម្រាប់សិង្ហបុរី រួមមាន ៖

(i) រដ្ឋាភិបាលនៃសាធារណរដ្ឋសិង្ហបុរី

(ii) អាជ្ញាធររូបិយវត្ថុនៃប្រទេសសិង្ហបុរី

(iii) ក្រុមហ៊ុន ជី អាយ ស៊ី ឯកជនទទួលខុសត្រូវមានកម្រិត

(iv) នីតិបុគ្គលសាធារណៈ និង

(v) ស្ថាប័នដទៃទៀតដូចដែលអាចព្រមព្រៀងគ្នានាពេលក្រោយ រវាងអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងទាំងពីរ។

៤-	ពាក្យ “ការប្រាក់” ដែលប្រើក្នុងមាត្រានេះសំដៅដល់ចំណូលពីបំណុលគ្រប់ប្រភេទ ទោះបីជាបានឬមិនបានធានាដោយការដាក់វត្ថុបញ្ចាំ និងមានឬគ្មានសិទ្ធិទទួលបានការបែងចែកប្រាក់ចំណេញរបស់កូនបំណុល និងជាពិសេសចំណូលដែលបានមកពីមូលបត្ររដ្ឋ និងចំណូលដែលបានមកពីសញ្ញាបណ្ណ ឬមូលបត្របំណុល រួមបញ្ចូលផងដែរនូវបុព្វលាភ និងរង្វាន់ដែលភ្ជាប់ជាមួយនឹងមូលបត្ររដ្ឋ សញ្ញាបណ្ណ ឬមូលបត្របំណុលទាំងនោះ ក៏ដូចជាចំនួនទឹកប្រាក់នានាដទៃទៀតដែលត្រូវបានចាត់ទុកជាប្រាក់ចំណូលបានពីការឱ្យខ្ចីដូចដែលបានកំណត់នៅក្នុងច្បាប់ដែលពាក់ព័ន្ធនឹងពន្ធដារនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀង ដែលប្រាក់ចំណូលកើតឡើង។ សម្រាប់គោលបំណងនៃមាត្រានេះ ប្រាក់ពិន័យដែលបានមកពីការបង់យឺតយ៉ាវ មិនត្រូវបានចាត់ទុកជាការប្រាក់ឡើយ។

៥-	បញ្ញត្តិនៃកថាខណ្ឌ១ និង២ មិនត្រូវយកមកអនុវត្ត ប្រសិនបើម្ចាស់សិទ្ធិអាស្រ័យផលនៃការប្រាក់ជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ប្រកបអាជីវកម្មនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀតដែលការប្រាក់នោះកើតឡើង តាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍ ឬបំពេញសេវាបុគ្គលឯករាជ្យតាមរយៈមូលដ្ឋានជាប់លាប់ដែលស្ថិតនៅរដ្ឋម្ខាងទៀតនោះ និងបំណុលដែលនាំឱ្យមានការទូទាត់ការប្រាក់នោះ មានទំនាក់ទំនងជាក់លាក់ ជាមួយគ្រឹះស្ថានអចិន្ត្រៃយ៍ ឬមូលដ្ឋានជាប់លាប់នោះ។ ចំពោះករណីនេះ បញ្ញត្តិនៃមាត្រា៧ ឬមាត្រា១៥ ត្រូវយកមកអនុវត្ត។

៦-	ការប្រាក់ត្រូវបានចាត់ទុកថាកើតឡើងនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង នៅពេលដែលអ្នកទូទាត់ការប្រាក់គឺជានិវាសនជននៃរដ្ឋនោះ។ ទោះបីបុគ្គលបង់ការប្រាក់ជានិវាសនជន ឬមិនមែនជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងក៏ដោយ ប៉ុន្តែមានគ្រឹះស្ថានអចិន្ត្រៃយ៍ ឬមូលដ្ឋានជាប់លាប់នៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀង ដែលមានការទាក់ទិននឹងបំណុលត្រូវបង់ការប្រាក់ ហើយការប្រាក់នោះត្រូវបានរ៉ាប់រងដោយគ្រឹះស្ថានអចិន្ត្រៃយ៍ ឬមូលដ្ឋានជាប់លាប់ ដូចនេះ ការប្រាក់នោះត្រូវបានចាត់ទុកថាកើតឡើងនៅក្នុងរដ្ឋដែលគ្រឹះស្ថានអចិន្ត្រៃយ៍ ឬមូលដ្ឋានជាប់លាប់ ស្ថិតនៅ។

៧-	ក្នុងករណី មានទំនាក់ទំនងពិសេសរវាងអ្នកទូទាត់ការប្រាក់និងម្ចាស់សិទ្ធិអាស្រ័យផល ឬរវាងបុគ្គលទាំងពីរ និងបុគ្គលដទៃទៀត ចំនួនការប្រាក់ដែលត្រូវទូទាត់ពាក់ព័ន្ធនឹងបំណុល មានចំនួនលើសពីចំនួនការប្រាក់ដែលបានព្រមព្រៀងរវាងអ្នកទូទាត់ការប្រាក់និងម្ចាស់សិទ្ធិអាស្រ័យផល ក្នុងករណីពុំមានទំនាក់ទំនងពិសេសបែបនោះ បញ្ញត្តិនៃមាត្រានេះ ត្រូវអនុវត្តចំពោះតែចំនួនទឹកប្រាក់ដែលភាគីទាំងពីរព្រមព្រៀងក្នុងករណីពុំមានទំនាក់ទំនងពិសេសប៉ុណ្ណោះ។ ក្នុងករណីនេះ ចំណែកលើសនៃការទូទាត់ ត្រូវជាប់ពន្ធស្របទៅតាមច្បាប់នៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងនីមួយៗ និងអនុលោមតាមបញ្ញត្តិផ្សេងទៀត នៃកិច្ចព្រមព្រៀងនេះ។

## មាត្រា ១២
## សួយសារ

១- សួយសារដែលកើតឡើងនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ហើយត្រូវបានទូទាត់ទៅឱ្យនិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត អាចជាប់ពន្ធនៅក្នុងរដ្ឋម្ខាងទៀតនោះ។

២- សួយសារនោះ ក៏អាចជាប់ពន្ធនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងដែលសួយសារនោះកើតឡើងផងដែរ និងអនុលោមតាមច្បាប់នៃរដ្ឋនោះ ប៉ុន្តែប្រសិនបើម្ចាស់សិទ្ធិអាស្រ័យផលនៃសួយសារនោះ ជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត បន្ទុកពន្ធដែលត្រូវបង់មិនត្រូវឱ្យលើសពី ១០ ភាគរយ នៃចំនួនដុល នៃសួយសារនោះទេ។

៣- ពាក្យ "សួយសារ" ដែលប្រើក្នុងមាត្រានេះ សំដៅដល់ការទូទាត់ណាមួយជាសំណងសម្រាប់ការប្រើប្រាស់ឬសិទ្ធិប្រើប្រាស់សិទ្ធិអ្នកនិពន្ធនៃស្នាដៃអក្សរសាស្ត្រ ការងារសិល្បៈឬវិទ្យាសាស្ត្រ ដែលរួមមាន ខ្សែភាពយន្តឬភាពយន្ត ឬខ្សែអាត់ដែលប្រើសម្រាប់ការចាក់ផ្សាយតាមវិទ្យុ ឬទូរទស្សន៍ ប្រកាសនីយបត្រតក្កកម្ម ពាណិជ្ជសញ្ញា ការរចនាម៉ូដឬម៉ូដែល ប្លង់ រូបមន្តឬរបៀបធ្វើសម្ងាត់ ឬសម្រាប់ការប្រើប្រាស់ ឬសិទ្ធិប្រើប្រាស់បរិក្ខារឧស្សាហកម្ម ពាណិជ្ជកម្ម ឬវិទ្យាសាស្ត្រ ឬសម្រាប់ព័ត៌មានដែលទាក់ទិននឹងបទពិសោធន៍ខាងឧស្សាហកម្ម ពាណិជ្ជកម្ម ឬវិទ្យាសាស្ត្រ។

៤- បញ្ញត្តិនៃកថាខណ្ឌ១ និង២ មិនត្រូវយកមកអនុវត្តទេ ប្រសិនបើម្ចាស់សិទ្ធិអាស្រ័យផលនៃសួយសារជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ប្រកបអាជីវកម្មនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀតដែលសួយសារកើតឡើង តាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍ ឬបំពេញសេវាបុគ្គលឯករាជ្យ តាមរយៈមូលដ្ឋានជាប់លាប់ដែលស្ថិតនៅរដ្ឋម្ខាងទៀតនោះ និងសិទ្ធិឬទ្រព្យដែលនាំឱ្យមានការទូទាត់សួយសារនោះ មានទំនាក់ទំនងជាក់លាក់ជាមួយគ្រឹះស្ថានអចិន្ត្រៃយ៍ ឬមូលដ្ឋានជាប់លាប់នោះ។ ចំពោះករណីនេះ បញ្ញត្តិនៃមាត្រា៧ ឬមាត្រា១៥ ត្រូវយកមកអនុវត្ត។

៥- សួយសារត្រូវបានចាត់ទុកថាកើតឡើងនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង នៅពេលដែលអ្នកបង់សួយសារគឺជានិវាសនជននៃរដ្ឋនោះ។ ទោះបីបុគ្គលបង់សួយសារជានិវាសនជន ឬមិនមែនជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងក៏ដោយ ប៉ុន្តែមានគ្រឹះស្ថានអចិន្ត្រៃយ៍ ឬមូលដ្ឋានជាប់លាប់នៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀង ដែលមានការទាក់ទិននឹងបំណុលនៃសួយសារត្រូវបង់ ហើយសួយសារនោះត្រូវបានរ៉ាប់រងដោយគ្រឹះស្ថានអចិន្ត្រៃយ៍ ឬមូលដ្ឋានជាប់លាប់ ដូចនេះសួយសារនោះត្រូវបានចាត់ទុកថាកើតឡើងនៅក្នុងរដ្ឋដែលគ្រឹះស្ថានអចិន្ត្រៃយ៍ ឬមូលដ្ឋានជាប់លាប់ ស្ថិតនៅ។

៦- ក្នុងករណី មានទំនាក់ទំនងពិសេសរវាងអ្នកបង់សួយសារនិងម្ចាស់សិទ្ធិអាស្រ័យផល ឬរវាងអ្នកទាំងពីរ និងបុគ្គលដទៃទៀត ចំនួនសួយសារដែលត្រូវបង់ពាក់ព័ន្ធនឹងការប្រើប្រាស់សិទ្ធិ ឬព័ត៌មាន មានចំនួនលើសពីចំនួនសួយសារដែលបានព្រមព្រៀងរវាងអ្នកបង់សួយសារ និងម្ចាស់សិទ្ធិអាស្រ័យផល ក្នុងករណីពុំមានទំនាក់ទំនងពិសេសបែបនោះ បញ្ញត្តិនៃមាត្រានេះ ត្រូវអនុវត្តចំពោះតែចំនួនទឹកប្រាក់ដែលភាគីទាំងពីរព្រមព្រៀងក្នុងករណីពុំមានទំនាក់ទំនងពិសេសប៉ុណ្ណោះ។ ក្នុងករណីនេះ ចំណែកលើសនៃការទូទាត់ ត្រូវជាប់ពន្ធស្របទៅតាមច្បាប់នៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងនីមួយៗ និងអនុលោមតាមបញ្ញត្តិផ្សេងទៀតនៃកិច្ចព្រមព្រៀងនេះ។

## មាត្រា ១៣
## កម្រៃសេវាបច្ចេកទេស

១- កម្រៃសេវាបច្ចេកទេសដែលកើតឡើងនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ហើយត្រូវបានទទួលដោយនិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត អាចជាប់ពន្ធនៅក្នុងរដ្ឋម្ខាងទៀតនោះ។

២- កម្រៃសេវាបច្ចេកទេសនោះ ក៏អាចជាប់ពន្ធនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀង ដែលកម្រៃសេវាបច្ចេក-ទេសនោះកើតឡើងផងដែរ និងអនុលោមតាមច្បាប់នៃរដ្ឋនោះ ប៉ុន្តែប្រសិនបើម្ចាស់សិទ្ធិអាស្រ័យផលនៃកម្រៃសេវាបច្ចេកទេសជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត បន្ទុកពន្ធដែលត្រូវបង់មិនត្រូវឱ្យលើសពី ១០ ភាគរយ នៃចំនួនដុល នៃកម្រៃសេវាបច្ចេកទេស។

៣- ពាក្យ “កម្រៃសេវាបច្ចេកទេស” សំដៅដល់ការទូទាត់គ្រប់ប្រភេទជាសំណងសម្រាប់ការបំពេញសេវាគ្រប់គ្រង បច្ចេកទេស ឬពិគ្រោះយោបល់ រួមបញ្ចូលទាំងការផ្តល់សេវាកម្មដោយសហគ្រាសតាមរយៈ បុគ្គលិកបច្ចេកទេស ឬបុគ្គលិកផ្សេងទៀត ប៉ុន្តែមិនរួមបញ្ចូលការទូទាត់លើសេវានានា ដែលមានចែងក្នុងមាត្រា១៥ នៃកិច្ចព្រមព្រៀងនេះ។

៤- បញ្ញត្តិនៃកថាខណ្ឌ១ និង២ នៃមាត្រានេះ មិនត្រូវអនុវត្តឡើយ ប្រសិនបើម្ចាស់សិទ្ធិអាស្រ័យផលនៃកម្រៃសេវាបច្ចេកទេសជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ប្រកបអាជីវកម្មនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀតដែលកម្រៃសេវាបច្ចេកទេសកើតឡើង តាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍ដែលស្ថិតនៅរដ្ឋម្ខាងទៀតនោះ ហើយកម្រៃសេវាបច្ចេកទេសនោះ មានទំនាក់ទំនងជាក់លាក់ជាមួយគ្រឹះស្ថានអចិន្ត្រៃយ៍នោះ។ ក្នុងករណីនេះ បញ្ញត្តិនៃមាត្រា៧ ត្រូវយកមកអនុវត្ត។

៥- កម្រៃសេវាបច្ចេកទេសត្រូវបានចាត់ទុកថាកើតឡើងនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង នៅពេលដែលអ្នកទូទាត់កម្រៃគឺជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងនោះ។ ទោះបីបុគ្គលទូទាត់កម្រៃសេវាបច្ចេកទេសជានិវាសនជន ឬមិនមែនជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងក៏ដោយ ប៉ុន្តែមានគ្រឹះស្ថានអចិន្ត្រៃយ៍ ឬមូលដ្ឋានជាប់លាប់នៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀង ដែលមានការទាក់ទិននឹងកាតព្វកិច្ចទូទាត់កម្រៃសេវាបច្ចេកទេសដែលកើតឡើង ហើយកម្រៃសេវាបច្ចេកទេសនោះត្រូវបានរ៉ាប់រងដោយគ្រឹះស្ថានអចិន្ត្រៃយ៍ ឬមូលដ្ឋានជាប់លាប់ទាំងនោះ ដូច្នេះ កម្រៃសេវាបច្ចេកទេសនោះត្រូវបានចាត់ទុកថាកើតឡើងនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងដែលគ្រឹះស្ថានអចិន្ត្រៃយ៍ ឬមូលដ្ឋានជាប់លាប់ ស្ថិតនៅ។

៦- ក្នុងករណី មានទំនាក់ទំនងពិសេសរវាងបុគ្គលទូទាត់កម្រៃសេវាបច្ចេកទេសនិងម្ចាស់សិទ្ធិអាស្រ័យផល ឬរវាងបុគ្គលទាំងពីរ និងបុគ្គលដទៃទៀត ទោះក្នុងហេតុផលណាក៏ដោយ កម្រៃសេវាបច្ចេកទេសដែលត្រូវទូទាត់ មានចំនួនលើសពីកម្រៃសេវាបច្ចេកទេស ដែលគួរតែបានព្រមព្រៀងរវាងបុគ្គលទូទាត់និងម្ចាស់សិទ្ធិអាស្រ័យផលក្នុងករណីពុំមានទំនាក់ទំនងពិសេសបែបនោះ ដូចនេះបញ្ញត្តិនៃមាត្រានេះ ត្រូវអនុវត្តចំពោះតែចំនួនទឹកប្រាក់ដែលភាគីទាំងពីរព្រមព្រៀង ក្នុងករណីពុំមានទំនាក់ទំនងពិសេសប៉ុណ្ណោះ។ ក្នុងករណីនេះ ចំណែកលើសនៃការទូទាត់ ត្រូវជាប់ពន្ធស្របទៅតាមច្បាប់នៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងនីមួយៗ និងអនុលោមតាមបញ្ញត្តិផ្សេងទៀតនៃកិច្ចព្រមព្រៀងនេះ។

## មាត្រា ១៤
## ចំណេញមូលធន

១- ចំណេញមូលធន ដែលទទួលបានដោយនិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ពីការលក់ឬផ្ទេរអចលនទ្រព្យ ដូចមានចែងក្នុងមាត្រា៦ ហើយដែលស្ថិតនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត អាចជាប់ពន្ធនៅក្នុងរដ្ឋម្ខាងទៀតនោះ។

២- ចំណេញមូលធនពីការលក់ឬផ្ទេរចលនទ្រព្យ ដែលជាចំណែកនៃទ្រព្យអាជីវកម្មរបស់គ្រឹះស្ថានអចិន្ត្រៃយ៍ ដែលសហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងមាននៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត ឬចំណេញមូលធនពីការលក់ឬផ្ទេរចលនទ្រព្យ ជាប់ទាក់ទិននឹងមូលដ្ឋានជាប់លាប់របស់និវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង នៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត សម្រាប់គោលដៅនៃការបំពេញសេវាបុគ្គលឯករាជ្យ រួមបញ្ចូលទាំងចំណេញមូលធនពីការលក់ឬផ្ទេរគ្រឹះស្ថានអចិន្ត្រៃយ៍(គ្រឹះស្ថានអចិន្ត្រៃយ៍តែឯង ឬជាមួយសហគ្រាសទាំងមូល) ឬពីការលក់ឬផ្ទេរមូលដ្ឋានជាប់លាប់ អាចជាប់ពន្ធនៅក្នុងរដ្ឋម្ខាងទៀតនោះ។

៣- ចំណេញមូលធនដែលទទួលបានដោយនិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ពីការលក់ឬផ្ទេរនាវា ឬយន្តហោះដែលប្រតិបត្តិការក្នុងចរាចរណ៍អន្តរជាតិ ឬពីការលក់ឬផ្ទេរចលនទ្រព្យដែលជាប់ទាក់ទិននឹងប្រតិបត្តិការនៃនាវា ឬយន្តហោះ ត្រូវជាប់ពន្ធតែនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងនោះ តែប៉ុណ្ណោះ។

៤- ចំណេញមូលធនដែលទទួលបានដោយនិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ពីការលក់ឬផ្ទេរភាគហ៊ុនដែលលើសពី ៥០ ភាគរយ នៃតម្លៃភាគហ៊ុននោះ បានមកដោយផ្ទាល់ឬដោយប្រយោលពីអចលនទ្រព្យ ដែលស្ថិតនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត អាចជាប់ពន្ធនៅក្នុងរដ្ឋម្ខាងទៀតនោះ។

៥- ចំណេញមូលធនពីការលក់ឬផ្ទេរទ្រព្យទាំងឡាយ ក្រៅពីទ្រព្យដូចមានចែងនៅក្នុងបណ្តាកថាខណ្ឌខាងលើនៃមាត្រានេះ ត្រូវជាប់ពន្ធតែនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀង ដែលអ្នកលក់ឬផ្ទេរជានិវាសនជន។

## មាត្រា ១៥
## សេវាបុគ្គលឯករាជ្យ

១- តាមបញ្ញត្តិនៃមាត្រា១៣ ប្រាក់ចំណូលដែលទទួលបានដោយរូបវន្តបុគ្គលដែលជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ពីការបំពេញសេវាវិជ្ជាជីវៈ ឬសកម្មភាពផ្សេងទៀតដែលមានចរិតលក្ខណៈឯករាជ្យ ត្រូវជាប់ពន្ធតែនៅក្នុងរដ្ឋម្ខាងនោះប៉ុណ្ណោះ លើកលែងតែករណីដូចខាងក្រោម ដែលប្រាក់ចំណូលទាំងនោះ ក៏អាចត្រូវជាប់ពន្ធនៅរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀតផងដែរ÷

ក. ប្រសិនបើរូបវន្តបុគ្គលនោះ មានមូលដ្ឋានជាប់លាប់ដែលគាត់ប្រើប្រាស់ជាប្រចាំនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត ក្នុងគោលបំណងបំពេញសកម្មភាពរបស់គាត់។ ក្នុងករណីនេះ មានតែចំណូលដែលសម្រេចបានតាមរយៈមូលដ្ឋានជាប់លាប់នោះប៉ុណ្ណោះ ដែលអាចត្រូវជាប់ពន្ធនៅរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀតនោះ ឬ

ខ. ប្រសិនបើរូបវន្តបុគ្គលនោះ មានវត្តមាននៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត មួយលើក ឬច្រើនលើកដែលសរុបលើសពី ១៨៣ថ្ងៃ ក្នុងរយៈពេល ១២ខែ ណាមួយ ហើយក្នុងករណីនេះ មានតែចំណូលទទួលបានពីសកម្មភាព ដែលបានបំពេញនៅក្នុងរដ្ឋម្ខាងទៀតនោះប៉ុណ្ណោះ ដែលអាចត្រូវជាប់ពន្ធនៅរដ្ឋនោះ។

២- ពាក្យ “សេវាវិជ្ជាជីវៈ” រួមបញ្ចូលជាពិសេសសកម្មភាពឯករាជ្យខាងវិទ្យាសាស្ត្រ អក្សរសាស្ត្រ សិល្បៈ អប់រំ ឬបង្រៀន ព្រមទាំងសកម្មភាពឯករាជ្យរបស់គ្រូពេទ្យ មេធាវី វិស្វករ ស្ថាបត្យករ ទន្តពេទ្យ និងគណនេយ្យករ។

## មាត្រា ១៦
## សេវាបុគ្គលមិនឯករាជ្យ

១- សម្រាប់គោលដៅបញ្ញត្តិនៃមាត្រា១៧ មាត្រា១៩ និងមាត្រា២០ ប្រាក់បៀវត្ស ប្រាក់ឈ្នួល និងលាភការប្រហាក់ប្រហែលផ្សេងទៀត ដែលទទួលបានដោយនិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ក្នុងការបំពេញការងារ ត្រូវជាប់ពន្ធតែក្នុងរដ្ឋម្ខាងនោះប៉ុណ្ណោះ វៀរលែងតែការបំពេញការងារនោះ ធ្វើឡើងនៅរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត។ ប្រសិនបើការបំពេញការងារនោះ ធ្វើឡើងនៅរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត លាភការដែលទទួលបាន អាចត្រូវជាប់ពន្ធនៅរដ្ឋម្ខាងទៀតនោះ។

២- ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌ១ ក៏ដោយ លាភការដែលទទួលបានដោយនិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ក្នុងការបំពេញការងារនៅរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត ត្រូវជាប់ពន្ធតែក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងដំបូងប៉ុណ្ណោះ ប្រសិនបើ÷

ក. អ្នកទទួលលាភការមានវត្តមាននៅក្នុងរដ្ឋម្ខាងទៀត មួយលើក ឬច្រើនលើកដែលសរុប មិនលើសពី ១៨៣ថ្ងៃ ក្នុងរយៈពេល ១២ខែ ណាមួយ និង

ខ. លាភការត្រូវបានបង់ដោយ ឬក្នុងនាមនិយោជកដែលមិនមែនជានិវាសនជននៃរដ្ឋម្ខាងទៀត និង

គ. លាភការមិនត្រូវបានរ៉ាប់រងដោយគ្រឹះស្ថានអចិន្ត្រៃយ៍ ឬមូលដ្ឋានជាប់លាប់ ដែលនិយោជកមាននៅរដ្ឋម្ខាងទៀត។

៣- ទោះបីជាមានបណ្ដាបញ្ញត្តិខាងលើនៃមាត្រានេះក៏ដោយ លាភការដែលទទួលបានក្នុងការបំពេញការងារនៅលើនាវា ឬយន្តហោះ ដែលប្រតិបត្តិការក្នុងចរាចរណ៍អន្តរជាតិដោយសហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង អាចត្រូវជាប់ពន្ធនៅក្នុងរដ្ឋនោះ។

## មាត្រា ១៧
## កម្រៃរបស់អភិបាល

កម្រៃ និងការទូទាត់ប្រហាក់ប្រហែលផ្សេងទៀត របស់អភិបាលដែលជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ក្នុងនាមជាសមាជិកនៃក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ដែលក្រុមហ៊ុននោះជានិវាសនជនរបស់រដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត អាចត្រូវជាប់ពន្ធនៅរដ្ឋម្ខាងទៀតនោះ។

## មាត្រា ១៨
## សិល្បករ និងកីឡាករ

១- ទោះបីជាមានបញ្ញត្តិនៃមាត្រា១៥ និងមាត្រា១៦ ក៏ដោយ ប្រាក់ចំណូលដែលទទួលបានដោយនិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ក្នុងនាមជាសិល្បករល្ខោន អ្នកសម្ដែងភាពយន្ត សិល្បករតាមវិទ្យុឬទូរទស្សន៍ ឬតន្ត្រីករ ឬក្នុងនាមជាកីឡាករ តាមរយៈសកម្មភាពផ្ទាល់ខ្លួនរបស់និវាសនជននោះ ដែលធ្វើឡើងនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត អាចត្រូវជាប់ពន្ធនៅក្នុងរដ្ឋម្ខាងទៀតនោះ។

២- ក្នុងករណីដែលប្រាក់ចំណូលរបស់សិល្បករ/អ្នកសម្ដែង ឬកីឡាករ សម្រេចបានតាមរយៈសកម្មភាពផ្ទាល់ខ្លួន ដែលប្រាក់ចំណូលនោះមិនបានបង្គរទុកនៅសិល្បករ/អ្នកសម្ដែង ឬកីឡាករនោះផ្ទាល់ ប៉ុន្តែត្រូវបានបង្គរទុកនៅបុគ្គលផ្សេងទៀត ដូចនេះប្រាក់ចំណូលនោះ អាចត្រូវជាប់ពន្ធនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងដែលសកម្មភាពរបស់សិល្បករ/អ្នកសម្ដែង ឬកីឡាករនោះ កើតឡើង ទោះបីជាមានបញ្ញត្តិនៃមាត្រា៧ មាត្រា១៥ និងមាត្រា១៦ ក៏ដោយ។

៣- ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌ១ និង២ ក៏ដោយ ប្រាក់ចំណូលដែលទទួលបានពីសកម្មភាពដូចមានចែងក្នុងកថាខណ្ឌ១ ដែលបានបំពេញក្រោមកិច្ចព្រមព្រៀង ឬកិច្ចសហការក្នុងផ្នែកវប្បធម៌រវាងរដ្ឋភាគីនៃកិច្ចព្រមព្រៀងទាំងពីរ មិនត្រូវជាប់ពន្ធនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងដែលសកម្មភាពនោះកើតឡើង ប្រសិនបើការធ្វើសកម្មភាពនៅក្នុងរដ្ឋភាគីនោះ បានទទួលការឧបត្ថម្ភទាំងស្រុង ឬស្ទើរតែទាំងស្រុងដោយមូលនិធិនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងណាមួយ ឬអាជ្ញាធរមូលដ្ឋាន ឬនីតិបុគ្គលសាធារណៈ ឬគ្រឹះស្ថានសាធារណៈ។

## មាត្រា ១៩
## ប្រាក់សោធននិវត្តន៍ និងការទូទាត់របបសន្តិសុខសង្គម

១- តាមបញ្ញត្តិនៃកថាខណ្ឌ២ នៃមាត្រា២០ ប្រាក់សោធននិវត្តន៍ និងលាភការប្រហាក់ប្រហែលផ្សេងទៀត ដែលបានទូទាត់ឱ្យនិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ចំពោះការបំពេញការងារកន្លងមក ត្រូវជាប់ពន្ធតែនៅរដ្ឋម្ខាងនោះប៉ុណ្ណោះ។

២- ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌ១ ក៏ដោយ ប្រាក់សោធននិវត្តន៍ និងប្រាក់ទូទាត់ផ្សេងៗ ដែលត្រូវបានទូទាត់ក្រោមកម្មវិធីសាធារណៈ ឬកម្មវិធីដែលជាផ្នែកមួយនៃប្រព័ន្ធសន្តិសុខសង្គមនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ឬអាជ្ញាធរមូលដ្ឋាន ឬនីតិបុគ្គលសាធារណៈ ត្រូវជាប់ពន្ធតែនៅក្នុងរដ្ឋម្ខាងនោះប៉ុណ្ណោះ។

## មាត្រា ២០
## ការបំពេញសេវាឱ្យរដ្ឋាភិបាល

១- ក. ប្រាក់បៀវត្ស ប្រាក់ឈ្នួល និងលាភការប្រហាក់ប្រហែលផ្សេងទៀត ដែលបានទូទាត់ដោយរដ្ឋភាគីនៃកិច្ចព្រមព្រៀង ឬអាជ្ញាធរមូលដ្ឋាន ឬនីតិបុគ្គលសាធារណៈនៃរដ្ឋភាគីម្ខាង ឱ្យទៅរូបវន្តបុគ្គលដែលបានបំពេញសេវាឱ្យរដ្ឋ ឬអាជ្ញាធរមូលដ្ឋាន ឬនីតិបុគ្គលសាធារណៈទាំងនោះ ត្រូវជាប់ពន្ធតែក្នុងរដ្ឋម្ខាងនោះប៉ុណ្ណោះ។

ខ. ប៉ុន្តែ ប្រាក់បៀវត្ស ប្រាក់ឈ្នួល និងលាភការប្រហាក់ប្រហែលផ្សេងទៀតខាងលើ ត្រូវជាប់ពន្ធតែនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀតប៉ុណ្ណោះ ប្រសិនបើសេវាត្រូវបានបំពេញនៅក្នុងរដ្ឋម្ខាងទៀតនោះ ដោយរូបវន្តបុគ្គលដែលជានិវាសនជននៃរដ្ឋនោះ÷

(i) ជាជនជាតិនៃរដ្ឋម្ខាងទៀតនោះ ឬ

(ii) មិនមែនជានិវាសនជនដោយគ្រាន់តែក្នុងគោលបំណងផ្តល់សេវាទាំងនោះតែប៉ុណ្ណោះ។

២- ក. ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌ១ ក៏ដោយ ប្រាក់សោធននិវត្តន៍ និងលាភការប្រហាក់ប្រហែលផ្សេងទៀត ដែលបានទូទាត់ដោយ ឬទទួលបានពីមូលនិធិដែលបង្កើតដោយរដ្ឋភាគីនៃកិច្ចព្រមព្រៀង ឬអាជ្ញាធរមូលដ្ឋាន ឬនីតិបុគ្គលសាធារណៈនៃរដ្ឋភាគីម្ខាងឱ្យទៅរូបវន្តបុគ្គលដែលបានបំពេញសេវាឱ្យរដ្ឋ ឬអាជ្ញាធរមូលដ្ឋាន ឬនីតិបុគ្គលសាធារណៈទាំងនោះ ត្រូវជាប់ពន្ធតែនៅក្នុងរដ្ឋម្ខាងនោះប៉ុណ្ណោះ។

ខ- ប៉ុន្តែ ប្រាក់សោធននិវត្តន៍ និងលាភការប្រហាក់ប្រហែលផ្សេងទៀតខាងលើ ត្រូវជាប់ពន្ធតែនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀតប៉ុណ្ណោះ ប្រសិនបើរូបវន្តបុគ្គលនោះ គឺជានិវាសនជន និងជាជនជាតិនៃរដ្ឋនោះ។

៣- បញ្ញត្តិនៃមាត្រា១៦ មាត្រា១៧ មាត្រា១៨ និងមាត្រា១៩ ត្រូវយកមកអនុវត្តចំពោះប្រាក់បៀវត្ស ប្រាក់ឈ្នួល ប្រាក់សោធននិវត្តន៍ និងលាភការប្រហាក់ប្រហែលផ្សេងទៀត ចំពោះការបំពេញសេវា ដែលទាក់ទិននឹងការប្រកបអាជីវកម្មរបស់រដ្ឋភាគីនៃកិច្ចព្រមព្រៀង ឬអាជ្ញាធរមូលដ្ឋាន ឬនីតិបុគ្គលសាធារណៈទាំងនោះ។

## មាត្រា ២១
## សិស្ស/និស្សិត

ការទូទាត់សម្រាប់ការទ្រទ្រង់ជីវភាព ឬអប់រំ ឬបណ្តុះបណ្តាលឱ្យសិស្ស/និស្សិត ឬអ្នកហាត់ការអាជីវកម្ម ឬកូនជាង ដែលជានិវាសនជន ឬថ្មីៗធ្លាប់ជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត មុនពេលចេញទៅបំពេញការសិក្សានៅរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង និងមានវត្តមាននៅក្នុងរដ្ឋម្ខាងនោះ សម្រាប់តែគោលបំណងនៃការសិក្សាឬបណ្តុះបណ្តាល មិនត្រូវជាប់ពន្ធនៅក្នុងរដ្ឋនោះឡើយ ប្រសិនបើការទូទាត់មានប្រភពពីខាងក្រៅរដ្ឋនោះ។

## មាត្រា ២២
## ប្រាក់ចំណូលផ្សេងទៀត

១- ខ្ទង់ចំណូលរបស់និវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀង ទោះកើតឡើងនៅកន្លែងណាក៏ដោយដែលមិនមានចែងនៅក្នុងបណ្តាមាត្រាទាំងឡាយខាងដើមនៃកិច្ចព្រមព្រៀងនេះ ត្រូវជាប់ពន្ធតែក្នុងរដ្ឋនោះប៉ុណ្ណោះ។

២- បញ្ញត្តិនៃកថាខណ្ឌ១ មិនត្រូវយកមកអនុវត្តចំពោះប្រាក់ចំណូលនានា ក្រៅពីប្រាក់ចំណូលបានពីអចលនទ្រព្យ ដូចបានកំណត់ក្នុងកថាខណ្ឌ២ នៃមាត្រា៦ ប្រសិនបើអ្នកទទួលប្រាក់ចំណូលនោះ ជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ប្រកបអាជីវកម្មក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត តាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍ ឬបំពេញសេវាបុគ្គលឯករាជ្យ តាមរយៈមូលដ្ឋានជាប់លាប់ ដែលស្ថិតនៅរដ្ឋម្ខាងទៀតនោះ និងសិទ្ធិ ឬទ្រព្យដែលនាំឱ្យមានការទូទាត់ប្រាក់ចំណូលនោះ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយគ្រឹះស្ថានអចិន្ត្រៃយ៍ ឬមូលដ្ឋានជាប់លាប់នោះ។ ចំពោះករណីនេះ បញ្ញត្តិនៃមាត្រា៧ ឬមាត្រា១៥ ត្រូវយកមកអនុវត្ត។

៣- ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌ១ និង២ ក៏ដោយ ខ្ទង់ចំណូលរបស់និវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ដែលមិនមានចែងនៅក្នុងបណ្តាមាត្រាទាំងឡាយខាងដើមនៃកិច្ចព្រមព្រៀងនេះ ហើយកើតឡើងក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត អាចត្រូវជាប់ពន្ធក្នុងរដ្ឋម្ខាងទៀតនោះ។

## មាត្រា ២៣
## វិធីសម្រាប់លុបបំបាត់ការយកពន្ធត្រួតគ្នា

ការយកពន្ធត្រួតគ្នាត្រូវលុបបំបាត់ដូចខាងក្រោម÷

ក. សម្រាប់កម្ពុជា÷

ក្នុងករណីនិវាសនជនកម្ពុជាទទួលបានប្រាក់ចំណូល ដែលអាចជាប់ពន្ធនៅប្រទេសសិង្ហបុរីដោយអនុលោមតាមបណ្តាបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ កម្ពុជាត្រូវអនុញ្ញាតឱ្យមានការកាត់កងពីពន្ធលើប្រាក់ចំណូលរបស់និវាសនជននោះ នូវចំនួនដែលស្មើនឹងប្រាក់ពន្ធបានបង់នៅសិង្ហបុរី។ ប៉ុន្តែ ការកាត់កងនេះមិនត្រូវឱ្យលើសពីចំណែកនៃពន្ធរបស់កម្ពុជាលើប្រាក់ចំណូល ដូចដែលបានគណនាមុនអនុញ្ញាតឱ្យមានការកាត់កង។

ខ. សម្រាប់សិង្ហបុរី÷

ក្នុងករណីនិវាសនជនសិង្ហបុរីទទួលបានប្រាក់ចំណូលពីប្រទេសកម្ពុជា អនុលោមតាមបណ្តាបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ អាចជាប់ពន្ធនៅក្នុងប្រទេសកម្ពុជា ដូចនេះសិង្ហបុរីត្រូវផ្តល់ឥណទានពន្ធចំពោះប្រាក់ពន្ធដែលបានទូទាត់នៅកម្ពុជា ទោះបីជាបានទូទាត់ដោយផ្ទាល់ ឬតាមរយៈការកាត់កងជាឥណទានធៀបទៅនឹងពន្ធដែលត្រូវបង់នៅប្រទេសសិង្ហបុរីចំពោះចំណូលរបស់និវាសនជននោះ ដោយអនុលោមតាមច្បាប់នានារបស់សិង្ហបុរីទាក់ទិននឹងការអនុញ្ញាតឱ្យមានការផ្តល់ជាឥណទានធៀបទៅនឹងពន្ធក្នុងប្រទេសសិង្ហបុរី ចំពោះប្រាក់ពន្ធដែលត្រូវបង់នៅប្រទេសណាមួយក្រៅពីប្រទេសសិង្ហបុរី។ ក្នុងករណីប្រាក់ចំណូលនេះជាភាគលាភ ដែលទូទាត់ដោយក្រុមហ៊ុនដែលជានិវាសជននៃប្រទេសកម្ពុជា ទៅឱ្យនិវាសជននៃប្រទេសសិង្ហបុរីដែលជាក្រុមហ៊ុនកាន់កាប់ដោយផ្ទាល់ឬប្រយោល មិនតិចជាង ១០ ភាគរយ នៃភាគហ៊ុនមូលធនរបស់ក្រុមហ៊ុនដែលនៅប្រទេសកម្ពុជា ឥណទានពន្ធត្រូវគិតបញ្ចូលផងដែរនូវប្រាក់ពន្ធដែលបានទូទាត់នៅប្រទេសកម្ពុជា ដោយក្រុមហ៊ុនលើចំណែកប្រាក់ចំណេញនៅប្រទេសកម្ពុជា លើភាគលាភដែលត្រូវបានបែងចែកពីប្រាក់ចំណេញនោះ។

## មាត្រា ២៤
## ការមិនរើសអើង

១- ជនជាតិនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង មិនត្រូវជាកម្មវត្ថុនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត ចំពោះការយកពន្ធ ឬតម្រូវការណាមួយដែលពាក់ព័ន្ធទៅនឹងពន្ធ ដែលខុសពីឬមានបន្ទុកលើសពីការយកពន្ធ ឬតម្រូវការដែលពាក់ព័ន្ធនឹងពន្ធ លើជនជាតិនៃរដ្ឋម្ខាងទៀតនោះ ក្នុងកាលៈទេសៈដូចគ្នាជាពិសេសទាក់ទិននឹងនិវាសនដ្ឋាន។

២- ការកំណត់ពន្ធចំពោះគ្រឹះស្ថានអចិន្ត្រៃយ៍ ដែលសហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងមាននៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត មិនត្រូវទទួលបានការអនុគ្រោះលើការយកពន្ធ តិចជាងសហគ្រាសរបស់រដ្ឋម្ខាងទៀតនោះ ដែលមានសកម្មភាពអាជីវកម្មដូចគ្នា។ បញ្ញត្តិនេះមិនត្រូវបានបកស្រាយថា រដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ត្រូវមានកាតព្វកិច្ចផ្តល់ការអនុគ្រោះឱ្យនិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀតនូវចំណូលផ្ទាល់ខ្លួន ការអនុគ្រោះ និងការកាត់បន្ថយ សម្រាប់គោលដៅសារពើពន្ធដោយសារតែស្ថានភាពគ្រួសារ ឬការទទួលខុសត្រូវក្នុងគ្រួសារ ដែលរដ្ឋម្ខាងនោះផ្តល់ឱ្យនិវាសនជនរបស់ខ្លួន។

៣- លើកលែងតែក្នុងករណីដែលបញ្ញត្តិនៃកថាខណ្ឌ១ នៃមាត្រា៩ កថាខណ្ឌ៧ នៃមាត្រា១១ កថាខណ្ឌ៦ នៃមាត្រា១២ ឬកថាខណ្ឌ៦ នៃមាត្រា១៣ យកមកអនុវត្ត សម្រាប់គោលដៅកំណត់ពន្ធប្រាក់ចំណេញរបស់សហគ្រាស ការប្រាក់ សួយសារ កម្រៃសេវាបច្ចេកទេស និងការចំណាយផ្សេងៗ ដែលបានទូទាត់ដោយសហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ទៅឱ្យនិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត ត្រូវកាត់កងបានក្រោមលក្ខខណ្ឌដូចគ្នា ដូចក្នុងករណីដែលការទូទាត់ទាំងនោះ ធ្វើឡើងចំពោះនិវាសនជននៃរដ្ឋភាគីដំបូង។

៤- សហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ដែលមូលធនរបស់សហគ្រាសនោះ ត្រូវបានកាន់កាប់ឬគ្រប់គ្រងទាំងស្រុងឬមួយផ្នែក ដោយផ្ទាល់ឬប្រយោល ដោយនិវាសនជនមួយឬច្រើននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត មិនត្រូវជាកម្មវត្ថុនៅក្នុងរដ្ឋភាគីដំបូង ចំពោះការយកពន្ធឬតម្រូវការណាមួយដែលពាក់ព័ន្ធទៅនឹងពន្ធ ដែលខុសពីឬមានបន្ទុកលើសពីការយកពន្ធឬតម្រូវការដែលពាក់ព័ន្ធនឹងពន្ធ ដែលត្រូវឬអាចអនុវត្តចំពោះសហគ្រាសប្រហាក់ប្រហែលគ្នាផ្សេងទៀតនៃរដ្ឋភាគីដំបូងនោះ។

៥- ក្នុងករណីរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ផ្តល់ការលើកទឹកចិត្តផ្នែកពន្ធដល់ជនជាតិរបស់ខ្លួន ដែលបានរៀបចំឡើងក្នុងគោលបំណងជំរុញការអភិវឌ្ឍសេដ្ឋកិច្ច ឬសង្គម ដោយអនុលោមតាមគោលនយោបាយជាតិ និងលក្ខណវិនិច្ឆ័យរបស់រដ្ឋនោះ គឺមិនត្រូវបកស្រាយថាជាការរើសអើង ក្រោមមាត្រានេះទេ។

៦- បញ្ញត្តិនៃមាត្រានេះ ត្រូវអនុវត្តលើពន្ធទាំងអស់ដែលជាកម្មវត្ថុនៃកិច្ចព្រមព្រៀងនេះ។

## មាត្រា ២៥
## នីតិវិធីនៃការព្រមព្រៀងទៅវិញទៅមក

១- ក្នុងករណីបុគ្គលម្នាក់យល់ឃើញថា រាល់វិធានការនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ឬទាំងសងខាងបង្កឱ្យ ឬនឹងបង្កឱ្យមានការយកពន្ធលើបុគ្គលនោះ ដោយមិនអនុលោមតាមបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ បុគ្គលនោះអាចដាក់បណ្ដឹងតវ៉ាទៅអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀង ដែលគាត់ជានិវាសនជន ឬទៅអាជ្ញាធរមានសមត្ថកិច្ចនៅរដ្ឋភាគីនៃកិច្ចព្រមព្រៀងដែលគាត់មានសញ្ជាតិ ប្រសិនបើបណ្ដឹងតវ៉ារបស់គាត់ស្ថិតក្រោមកថាខណ្ឌ១ នៃមាត្រា២៤ ដោយពុំគិតពីដំណោះស្រាយតាមច្បាប់ក្នុងស្រុកនៃរដ្ឋទាំងនោះ។ ការដាក់បណ្ដឹងតវ៉ាត្រូវធ្វើឡើងក្នុងរយៈពេល ០៣ឆ្នាំ គិតចាប់ពីថ្ងៃជូនដំណឹងលើកដំបូងអំពីវិធានការនៃការយកពន្ធដែលមិនអនុលោមតាមបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ។

២- ប្រសិនបើបណ្ដឹងតវ៉ាមានហេតុផលត្រឹមត្រូវ ហើយអាជ្ញាធរមានសមត្ថកិច្ចមិនអាចផ្ដល់នូវដំណោះស្រាយណាមួយដែលជាទីពេញចិត្តបានទេនោះ អាជ្ញាធរមានសមត្ថកិច្ចត្រូវខិតខំដោះស្រាយបណ្ដឹងតវ៉ានោះតាមរយៈការព្រមព្រៀងទៅវិញទៅមកជាមួយអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត ក្នុងគោលបំណងចៀសវាងការយកពន្ធដែលមិនអនុលោមតាមកិច្ចព្រមព្រៀងនេះ។ ការព្រមព្រៀងដែលសម្រេចបាន ត្រូវអនុវត្តដោយមិនគិតពីរយៈពេលកំណត់របស់ច្បាប់ក្នុងស្រុកនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងទាំងពីរ។

៣- អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងទាំងសងខាង ត្រូវខិតខំដោះស្រាយរាល់បញ្ហា ឬចម្ងល់ផ្សេងៗដែលកើតឡើងពាក់ព័ន្ធនឹងការបកស្រាយ ឬការអនុវត្តកិច្ចព្រមព្រៀង តាមរយៈការព្រមព្រៀងទៅវិញទៅមក។ អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋទាំងសងខាងអាចពិភាក្សាគ្នាផងដែរ ក្នុងគោលបំណងលុបបំបាត់ការយកពន្ធត្រួតគ្នា ទោះជាក្នុងករណីមិនមានចែងក្នុងកិច្ចព្រមព្រៀងនេះ។

៤- អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងទាំងសងខាង អាចធ្វើទំនាក់ទំនងគ្នាដោយផ្ទាល់ ក្នុងគោលបំណងឈានទៅដល់ការសម្រេចការព្រមព្រៀងគ្នាមួយ ស្របតាមបណ្ដាកថាខណ្ឌខាងលើ។

## មាត្រា ២៦
## ការផ្លាស់ប្តូរព័ត៌មាន

១- អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងទាំងសងខាងត្រូវផ្លាស់ប្តូរព័ត៌មានទាំងឡាយ ដែលអាចរំពឹងទុកថាពាក់ព័ន្ធនឹងការអនុវត្តបញ្ញត្តិនានានៃកិច្ចព្រមព្រៀងនេះ ឬពាក់ព័ន្ធនឹងការគ្រប់គ្រងការអនុវត្ត ឬការដាក់បង្ខំឱ្យប្រតិបត្តិច្បាប់នានាក្នុងស្រុកទាក់ទិននឹងពន្ធគ្រប់ប្រភេទ និងគ្រប់ការបរិយាយដែលបានកំណត់ក្នុងនាមរដ្ឋភាគីនៃកិច្ចព្រមព្រៀង ឬអាជ្ញាធរមូលដ្ឋាន ដរាបណាការកំណត់ពន្ធមិនផ្ទុយនឹងកិច្ចព្រមព្រៀងនេះ។ ការផ្លាស់ប្តូរព័ត៌មានមិនត្រូវបានកំហិតដោយមាត្រា១ និងមាត្រា២ ឡើយ។

២- ព័ត៌មានដែលទទួលបានក្រោមកថាខណ្ឌ១ ដោយរដ្ឋភាគីនៃកិច្ចព្រមព្រៀងត្រូវរក្សាទុកជាការសម្ងាត់ក្នុងលក្ខណៈដូចគ្នានឹងព័ត៌មានដែលទទួលបានក្រោមច្បាប់ក្នុងស្រុកនៃរដ្ឋនោះ និងត្រូវផ្តល់ឱ្យតែចំពោះបុគ្គល ឬអាជ្ញាធរ (រួមមានតុលាការ និងស្ថាប័នរដ្ឋបាលនានា) ទាក់ទិននឹងការកំណត់ ឬការប្រមូលពន្ធ ការដាក់បង្ខំឱ្យប្រតិបត្តិ ឬការចោទប្រកាន់តាមផ្លូវច្បាប់ ការសម្រេចលើបណ្តឹងតវ៉ាដែលពាក់ព័ន្ធទៅនឹងពន្ធដូចមានចែងក្នុងកថាខណ្ឌ១ ឬការត្រួតពិនិត្យលើសកម្មភាពដូចបានរៀបរាប់ខាងលើ។ បុគ្គល ឬអាជ្ញាធរនោះ ត្រូវប្រើប្រាស់ព័ត៌មានសម្រាប់តែក្នុងគោលបំណង ដូចបានរៀបរាប់ខាងលើប៉ុណ្ណោះ។ បុគ្គល ឬអាជ្ញាធរនោះ អាចបង្ហាញព័ត៌មានបាននៅក្នុងដំណើរការនីតិវិធីតុលាការសាធារណៈ ឬនៅក្នុងសេចក្តីសម្រេចរបស់តុលាការ។

៣- ទោះក្នុងករណីណាក៏ដោយ បញ្ញត្តិនៃកថាខណ្ឌ១ និង២ នៃមាត្រានេះ មិនត្រូវបានបកស្រាយថាជាការដាក់កំហិតឱ្យរដ្ឋភាគីនៃកិច្ចព្រមព្រៀងមានកាតព្វកិច្ច÷

ក. ចាត់វិធានការផ្នែករដ្ឋបាលដែលមិនស្របតាមច្បាប់ និងការអនុវត្តការងាររដ្ឋបាលរបស់រដ្ឋភាគីនៃកិច្ចព្រមព្រៀងនោះ ឬរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត។

ខ. ផ្តល់ព័ត៌មានដែលមិនអាចទទួលបានក្រោមច្បាប់ ឬដំណើរការរដ្ឋបាលជាប្រក្រតីនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងនោះ ឬរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត។

គ. ផ្តល់ព័ត៌មានដែលបង្ហាញពីការសម្ងាត់ជំនួញ ធុរកិច្ច ឧស្សាហកម្ម ពាណិជ្ជកម្ម ឬវិជ្ជាជីវៈ ឬដំណើរការជំនួញ ឬព័ត៌មានដែលផ្ទុយនឹងគោលនយោបាយសាធារណៈ (សណ្តាប់ធ្នាប់សាធារណៈ)។

## មាត្រា ២៧
## សមាជិកបេសកកម្មទូត និងស្ថានកុងស៊ុល

កិច្ចព្រមព្រៀងនេះ មិនត្រូវប៉ះពាល់ដល់បុព្វសិទ្ធិសារពើពន្ធរបស់សមាជិកបេសកកម្មទូត ឬស្ថានកុងស៊ុល ក្រោមវិធានទូទៅនៃច្បាប់អន្តរជាតិ ឬក្រោមបទប្បញ្ញត្តិនៃការព្រមព្រៀងពិសេសនានា។

## មាត្រា ២៨
## ការចូលជាធរមាន

១- រដ្ឋភាគីនៃកិច្ចព្រមព្រៀងនីមួយៗត្រូវជូនដំណឹងទៅរដ្ឋភាគីម្ខាងទៀត តាមរយៈផ្លូវទូត អំពីការបំពេញចប់សព្វគ្រប់នូវនីតិវិធីដែលតម្រូវដោយច្បាប់ក្នុងស្រុក ដើម្បីឱ្យកិច្ចព្រមព្រៀងនេះចូលជាធរមាន។ កិច្ចព្រមព្រៀងនេះនឹងត្រូវចូលជាធរមាន នៅកាលបរិច្ឆេទនៃការទទួលបានការជូនដំណឹងក្រោយគេ។

២- កិច្ចព្រមព្រៀងនេះត្រូវមានប្រសិទ្ធភាពអនុវត្ត÷

ក. សម្រាប់កម្ពុជា÷

(i) ចំពោះពន្ធកាត់ទុកនៅប្រទេសប្រភព លើចំនួនប្រាក់ជាប់ពន្ធដែលកើតឡើងនៅថ្ងៃទីមួយនៃខែមករា ឬថ្ងៃបន្ទាប់ ក្នុងឆ្នាំប្រតិទិនបន្ទាប់ពីឆ្នាំដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន និងឆ្នាំប្រតិទិនបន្តបន្ទាប់ទៀត

(ii) ចំពោះពន្ធដទៃទៀត លើប្រាក់ចំណូលដែលកើតឡើងនៅថ្ងៃទីមួយនៃខែមករា ឬថ្ងៃបន្ទាប់ក្នុងឆ្នាំប្រតិទិនបន្ទាប់ពីឆ្នាំដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន និងឆ្នាំប្រតិទិនបន្តបន្ទាប់ទៀត និង

(iii) ចំពោះមាត្រា២៦ (ការផ្លាស់ប្តូរព័ត៌មាន) សម្រាប់សំណើដែលធ្វើឡើងនៅកាលបរិច្ឆេទ ឬក្រោយកាលបរិច្ឆេទចូលជាធរមាន អំពីព័ត៌មានពន្ធទាក់ទិននឹងរយៈពេលជាប់ពន្ធ ចាប់ផ្តើមនៅថ្ងៃទីមួយនៃខែមករា ឬថ្ងៃបន្ទាប់ ក្នុងឆ្នាំប្រតិទិនបន្ទាប់ពីឆ្នាំដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន ឬក្នុងករណីពុំមានរយៈពេលជាប់ពន្ធ សម្រាប់ព័ត៌មានពន្ធទាក់ទិននឹងរាល់បន្ទុកពន្ធដែលកើតឡើងនៅថ្ងៃទីមួយនៃខែមករាឬថ្ងៃបន្ទាប់ ក្នុងឆ្នាំប្រតិទិនបន្ទាប់ពីឆ្នាំដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន។

ខ. សម្រាប់សិង្ហបុរី÷

(i) ចំពោះពន្ធកាត់ទុកនៅប្រទេសប្រភព លើចំនួនទឹកប្រាក់ដែលជាបន្ទុកត្រូវបង់ ចាត់ទុកថាបានបង់ ឬបានបង់រួច (មួយណាដែលកើតឡើងដំបូងបំផុត) នៅថ្ងៃទីមួយនៃខែមករា ឬថ្ងៃបន្ទាប់ ក្នុងឆ្នាំប្រតិទិនបន្ទាប់ពីឆ្នាំដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន

(ii) ចំពោះពន្ធដែលត្រូវបង់ (ក្រៅពីពន្ធកាត់ទុកនៅក្នុងប្រទេសប្រភព) សម្រាប់ឆ្នាំកំណត់ពន្ធណាមួយ ដែលចាប់ផ្តើមឡើងនៅថ្ងៃទីមួយនៃខែមករា ឬថ្ងៃបន្ទាប់ ក្នុងឆ្នាំប្រតិទិនទីពីរ បន្ទាប់ពីឆ្នាំដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន និង

(iii) ចំពោះមាត្រា២៦ (ការផ្លាស់ប្តូរព័ត៌មាន) សម្រាប់សំណើដែលធ្វើឡើងនៅកាលបរិច្ឆេទ ឬក្រោយកាលបរិច្ឆេទចូលជាធរមាន អំពីព័ត៌មានពន្ធទាក់ទិននឹងរយៈពេលជាប់ពន្ធ ចាប់ផ្តើមនៅថ្ងៃទីមួយនៃខែមករា ឬថ្ងៃបន្ទាប់ ក្នុងឆ្នាំប្រតិទិនបន្ទាប់ពីឆ្នាំដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន ឬក្នុងករណីពុំមានរយៈពេលជាប់ពន្ធ សម្រាប់ព័ត៌មានពន្ធទាក់ទិននឹងរាល់បន្ទុកពន្ធដែលកើតឡើងនៅថ្ងៃទីមួយនៃខែមករា ឬថ្ងៃបន្ទាប់ ក្នុងឆ្នាំប្រតិទិនបន្ទាប់ពីឆ្នាំដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន។

## មាត្រា ២៩
## ការបញ្ចប់

កិច្ចព្រមព្រៀងនេះត្រូវនៅជាធរមាន រហូតដល់ពេលត្រូវបានបញ្ចប់ដោយរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង។ រដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងអាចបញ្ចប់កិច្ចព្រមព្រៀងនេះតាមរយៈផ្លូវទូត ដោយជូនដំណឹងស្ដីពីការបញ្ចប់យ៉ាងយូរត្រឹមថ្ងៃទី៣០ ខែមិថុនា នៃឆ្នាំប្រតិទិនណាមួយ ក្រោយពីការផុតកំណត់រយៈពេលប្រាំឆ្នាំ ចាប់ពីកាលបរិច្ឆេទដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន។ ក្នុងករណីនេះ កិច្ចព្រមព្រៀងត្រូវឈប់មានប្រសិទ្ធិភាពអនុវត្ត÷

ក. សម្រាប់កម្ពុជា÷

(i) ចំពោះពន្ធកាត់ទុកនៅប្រទេសប្រភព លើចំនួនប្រាក់ជាប់ពន្ធដែលបានកើតឡើងនៅថ្ងៃទីមួយនៃខែមករា ឬថ្ងៃបន្ទាប់ ក្នុងឆ្នាំប្រតិទិនបន្ទាប់ពីឆ្នាំនៃការជូនដំណឹងស្ដីពីការបញ្ចប់កិច្ចព្រមព្រៀងនេះ

(ii) ចំពោះពន្ធដទៃទៀត លើប្រាក់ចំណូលដែលបានកើតឡើងនៅថ្ងៃទីមួយនៃខែមករា ឬថ្ងៃបន្ទាប់ ក្នុងឆ្នាំប្រតិទិនបន្ទាប់ពីឆ្នាំនៃការជូនដំណឹង ស្ដីពីការបញ្ចប់កិច្ចព្រមព្រៀងនេះ និង

(iii) ក្នុងករណីផ្សេងទៀត រួមបញ្ចូលទាំងសំណើដែលធ្វើឡើងក្រោមមាត្រា២៦ (ការផ្លាស់ប្ដូរព័ត៌មាន) ក្រោយដំណាច់ឆ្នាំនៃឆ្នាំប្រតិទិន ដែលមានការជូនដំណឹងស្ដីពីការបញ្ចប់កិច្ចព្រមព្រៀងនេះ។

ខ. សម្រាប់សិង្ហបុរី÷

(i) ចំពោះពន្ធកាត់ទុកនៅប្រទេសប្រភព លើចំនួនទឹកប្រាក់ដែលត្រូវបង់ ចាត់ទុកថាបានបង់ ឬបានបង់រួច (មួយណាដែលកើតឡើងដំបូងបំផុត) ក្រោយដំណាច់ឆ្នាំនៃឆ្នាំប្រតិទិន ដែលជូនដំណឹងស្ដីពីការបញ្ចប់កិច្ចព្រមព្រៀងនេះ

(ii) ចំពោះពន្ធដែលត្រូវបង់ (ក្រៅពីពន្ធកាត់ទុកនៅក្នុងប្រទេសប្រភព) សម្រាប់ឆ្នាំកំណត់ពន្ធណាមួយ ដែលចាប់ផ្ដើមឡើងនៅថ្ងៃទីមួយនៃខែមករា ឬថ្ងៃបន្ទាប់ ក្នុងឆ្នាំប្រតិទិនទីពីរ បន្ទាប់ពីឆ្នាំដែលមានការជូនដំណឹងស្ដីពីការបញ្ចប់កិច្ចព្រមព្រៀងនេះ និង

(iii) ក្នុងករណីផ្សេងៗទៀត រួមបញ្ចូលទាំងសំណើដែលធ្វើឡើងក្រោមមាត្រា២៦ (ការផ្លាស់ប្ដូរព័ត៌មាន) ក្រោយដំណាច់ឆ្នាំនៃឆ្នាំប្រតិទិន ដែលមានការជូនដំណឹងស្ដីពីការបញ្ចប់កិច្ចព្រមព្រៀងនេះ។

ដើម្បីជាសក្ខីភាព   អ្នកតំណាងស្របច្បាប់ដែលបានទទួលសិទ្ធិអំណាចគ្រប់គ្រាន់   បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ។ ធ្វើជាពីរច្បាប់ នៅសិង្ហបុរី ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៦ ជាភាសាអង់គ្លេស។

| | |
|---|---|
| **សម្រាប់រាជរដ្ឋាភិបាលនៃ** | **សម្រាប់រដ្ឋាភិបាលនៃ** |
| **ព្រះរាជាណាចក្រកម្ពុជា** | **សាធារណរដ្ឋសិង្ហបុរី** |
| **បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន** | **អ៊ីនដ្រានី រ៉ាចា** |
| **ទេសរដ្ឋមន្ត្រី** | **ទេសរដ្ឋមន្ត្រី** |
| **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** | **រដ្ឋមន្ត្រីក្រសួងច្បាប់ និងហិរញ្ញវត្ថុ** |

## ពិធីសារ

ក្នុងពេលចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគេចវេសពន្ធ និងការបង្ការការគិបកេងបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលសាធារណរដ្ឋសិង្ហបុរីបានឯកភាពថា បញ្ញត្តិខាងក្រោមត្រូវក្លាយជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះ។

១- យោងតាមកិច្ចព្រមព្រៀងនេះ ពាក្យ "នីតិបុគ្គលសាធារណៈ" សំដៅដល់បុគ្គលដែលបង្កើតឡើងដោយច្បាប់ និងបំពេញមុខងារមិនមានលក្ខណៈពាណិជ្ជកម្ម ដែលមុខងារនោះគួរត្រូវបំពេញដោយរដ្ឋាភិបាលនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀង។

២- រដ្ឋភាគីនៃកិច្ចព្រមព្រៀងទាំងពីរឯកភាពថា ក្នុងករណីប្រទេសសិង្ហបុរី កថាខណ្ឌ២ នៃមាត្រា១៩ (ប្រាក់សោធននិវត្តន៍ និងប្រព័ន្ធសន្តិសុខសង្គម) ត្រូវអនុវត្តចំពោះការទូទាត់ដែលធ្វើឡើងក្រោមសិនត្រាល់ប្រូវីដិនហ្វាន់។

៣- រដ្ឋភាគីនៃកិច្ចព្រមព្រៀងទាំងពីរឯកភាពថា ទោះបីជាមានកថាខណ្ឌ៣ នៃមាត្រា២៤ (ការមិនរើសអើង) ក៏ដោយ សម្រាប់គោលបំណងនៃការអនុញ្ញាតឱ្យមានការកាត់កងចំពោះការទូទាត់ការប្រាក់ឱ្យអនិវាសនជន បញ្ញត្តិនៃកថាខណ្ឌនេះ មិនត្រូវរារាំងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងពីការមិនអនុញ្ញាតឱ្យមានការកាត់កងចំពោះការទូទាត់ការប្រាក់នេះ ប្រសិនបើពន្ធមិនត្រូវបានកាត់ទុកលើការទូទាត់នេះ។

៤- យោងតាមមាត្រា២៦ (ការផ្លាស់ប្តូរព័ត៌មាន) រដ្ឋភាគីនៃកិច្ចព្រមព្រៀងទាំងពីរឯកភាពថា កថាខណ្ឌខាងក្រោមមិនត្រូវបានដាក់បញ្ចូលទៅក្នុងមាត្រានេះ ដោយសារកថាខណ្ឌទាំងនេះមានវិសមិតភាព ជាមួយនឹងច្បាប់របស់កម្ពុជា÷

"៤- ប្រសិនបើព័ត៌មានត្រូវបានស្នើសុំដោយរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង អនុលោមតាមមាត្រានេះ រដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀតត្រូវប្រើវិធានការក្នុងការប្រមូលព័ត៌មាន ដើម្បីប្រមូលព័ត៌មានដែលបានស្នើសុំ ទោះបីជារដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀតនោះ មិនត្រូវការព័ត៌មាននោះសម្រាប់ប្រើក្នុងគោលដៅពន្ធរបស់ខ្លួនក៏ដោយ។ កាតព្វកិច្ចដែលមានចែងក្នុងប្រយោគមុននេះ គឺអាស្រ័យលើដែនកំណត់នៃកថាខណ្ឌ៣ ប៉ុន្តែពុំមានការបកស្រាយថា ដែនកំណត់ទាំងនេះអនុញ្ញាតឱ្យរដ្ឋភាគីនៃព្រមព្រៀងបដិសេធក្នុងការផ្តល់ព័ត៌មាន ដោយសារតែព័ត៌មាននោះពុំមានផលប្រយោជន៍ក្នុងស្រុក។

៥- ពុំមានករណីដែលបញ្ញត្តិនៃកថាខណ្ឌ៣ ត្រូវបានបកស្រាយថាមានការអនុញ្ញាតឱ្យរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងបដិសេធក្នុងការផ្តល់ព័ត៌មាន ដោយសារតែព័ត៌មាននោះកាន់កាប់ដោយធនាគារ

គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត អ្នកដែលត្រូវបានចាត់តាំង ឬបុគ្គលប្រតិបត្តិក្នុងនាមជាភ្នាក់ងារ ឬមានសមត្ថកិច្ច ឬដោយសារតែព័ត៌មាននោះ ទាក់ទិននឹងផលប្រយោជន៍នៃភាពជាម្ចាស់របស់បុគ្គលណាមួយឡើយ។"

រដ្ឋភាគីនៃកិច្ចព្រមព្រៀងទាំងពីរបានឯកភាពថា ក្នុងករណីកថាខណ្ឌទាំងពីរនេះអាចអនុវត្តបានស្របតាមច្បាប់របស់កម្ពុជា អាជ្ញាធរមានសមត្ថកិច្ចកម្ពុជាត្រូវជូនព័ត៌មានដល់អាជ្ញាធរមានសមត្ថកិច្ចសិង្ហបុរី ហើយមាត្រា២៦ នេះ ត្រូវធ្វើវិសោធនកម្មស្របទៅតាមនីតិវិធីផ្ទៃក្នុងរបស់រដ្ឋភាគីនៃកិច្ចព្រមព្រៀងទាំងពីរ។

ដើម្បីជាសក្ខីភាព អ្នកតំណាងស្របច្បាប់ដែលបានទទួលសិទ្ធិអំណាច បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ។

ធ្វើជាពីរច្បាប់ នៅសិង្ហបុរី ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៦ ជាភាសាអង់គ្លេស។

**សម្រាប់រាជរដ្ឋាភិបាលនៃ**
**ព្រះរាជាណាចក្រកម្ពុជា**

**បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន**
**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**សម្រាប់រដ្ឋាភិបាលនៃ**
**សាធារណរដ្ឋសិង្ហបុរី**

**អ៊ីនជ្រានី រ៉ាហ្សា**
**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងច្បាប់ និងហិរញ្ញវត្ថុ**